# របាយការណ៍សកម្មភាពប្រចាំឆ្នាំអង្គការលីកាដូ

## លើកកំពស់ និងការពារសិទ្ធិមនុស្សនៅកម្ពុជា

## មករា-ធ្នូ ២០០៧



សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION
AND DEFENSE OF HUMAN RIGHTS

# មាតិកា

ព័ត៌មានទូទៅ/ការងាររដ្ឋបាល-------------------------------------------------------១

ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស------------------------------------------------៤

ការិយាល័យសិទ្ធិស្ត្រី-------------------------------------------------------------៩

ការិយាល័យសិទ្ធិកុមារ-----------------------------------------------------------  ១៦

ការិយាល័យប្រឆាំងនឹងអំពើទារុណកម្ម-----------------------------------------------  ២៧

ការិយាល័យពេទ្យ---------------------------------------------------------------៣១

ការិយាល័យទាក់ទាញមតិគាំទ្រ ធនធានឯកសារ និងព័ត៌មាន--------------------------------------៣៧

ការិយាល័យអប់រំសិទ្ធិមនុស្ស-------------------------------------------------------  ៤២

## ព័ត៌មានទូទៅ/ការងាររដ្ឋបាល

នៅចុងឆ្នាំ ២០០៧នេះ មានបុគ្គលិកចំនួន ១៥៥នាក់ ដែលបានធ្វើការមិនពេញម៉ោង និងពេញម៉ោង រួមទាំងបុគ្គលិកស្ត្រីចំនួន ៥៣នាក់ ដែលកំពុងធ្វើការនៅការិយាល័យអង្គការលីកាដូភ្នំពេញ និងការិយាល័យអង្គការលីកាដូទាំង១២ ខេត្ត-ក្រុង។ នៅក្នុងឆ្នាំនេះមានបុគ្គលិកអង្គការលីកាដូ ៣៣នាក់ បានលាលែងពីតំណែង ហើយអង្គការលីកាដូបានជ្រើសរើសបុគ្គលិកថ្មីចំនួន ១៨នាក់ ហើយមានបុគ្គលិកចំនួន ២០នាក់បានប្តូរពីការិយាល័យមួយទៅការិយាល័យមួយ ទៀត និងបុគ្គលិកមួយចំនួនទៀតត្រូវបានតំឡើងឋានៈ។

គណៈកម្មាធិការរបស់អង្គការលីកាដូមានដូចជា លោកស្រីប្រធាន នាយិកា និងអ្នកសម្របសម្រួលភ្នំពេញ បានជួបប្រជុំ គ្នា ២៨ដង នៅក្នុងឆ្នាំ ២០០៧នេះ នៅរៀងរាល់រសៀលថ្ងៃសុក្រដើម្បីធ្វើការដោះស្រាយឧបសគ្គនានា ដែលជះឥទ្ធិពល លើប្រតិបត្តិការការងាររបស់ការិយាល័យនិមួយៗ។ អ្នកសម្របសម្រួលខេត្តនៃអង្គលីកាដូបានជួបប្រជុំជាមួយអ្នកសម្របសម្រួលភ្នំពេញ ១១ដង ក្នុងរយៈពេលមួយឆ្នាំ ក្នុងរវាងមួយថ្ងៃទៅបីថ្ងៃដើម្បីធ្វើការផ្លាស់ប្តូរបទពិសោធន៍ និងកំណត់យកយុទ្ធសាស្ត្រថ្មីដើម្បីអនុវត្តន៍គំរោង ការងារ។

នៅក្នុងឆ្នាំ ២០០៧ បុគ្គលិកអង្គការលីកាដូបំពេញបេសកកម្មបានចំនួន ២៨៧ ក្នុង ១៦ ខេត្ត-ក្រុង (រួមទាំងខេត្តចំនួន បួនទៀតដែលអង្គការលីកាដូមិនមានការិយាល័យជាអចិន្ត្រៃយ៍នៅទីនោះ ប៉ុន្តែយើងទទួលការស្នើរសុំពីអង្គការដៃគូរ ផ្សេងៗទៀត) ដើម្បីធ្វើការស៊ើបអង្កេត និងជួយដល់ជនរងគ្រោះដោយករណីរំលោភសិទ្ធិមនុស្ស និងដើម្បីធ្វើការទំនាក់ទំនងជាមួយមនុស្សដទៃទៀតដែលជាប់ទាក់ទងនៅក្នុងរឿងទាំងអស់នេះ។ បុគ្គលិកលីកាដូ បានធ្វើការចែកអាហារ និងផ្តល់ជំនួយមនុស្សធម៌រយៈពេលខ្លីដល់ជនរងគ្រោះចំនួន ២៩២០ នាក់ នៅទីក្រុងភ្នំពេញ និងនៅ ១១ ខេត្ត។

លីកាដូ គឺជាសហប្រធាននៃគណៈកម្មាធិការស្ត្រីកម្ពុជា (CAMBOW) គណៈកម្មាធិការនេះបានរៀបចំសកម្មភាពទាក់ទាញមតិគាំទ្រដោយបង្កើតលិខិតសេចក្តីថ្លែងការណ៍ ឧបករណ៍ផ្សព្វផ្សាយព័ត៌មាន និងការរៀបចំវេទិការសាធារណៈ។ អង្គការលីកាដូ គឺជាសមាជិកសកម្មរបស់សហព័ន្ធអន្តរជាតិដើម្បីអ្នកការពារសិទ្ធិមនុស្ស (FIDH) វេទិកាអាស៊ី (FA) ក្រុមការងារពិសេសសិទ្ធិលំនៅឋាន (HRTF) និង វេទិកាអង្គការមិនមែនរដ្ឋាភិបាល នៅកម្ពុជា។

នៅក្នុងឆ្នាំ ២០០៧ មានបុគ្គលិកលីកាដូចំនួន ៣៧នាក់ ទទួលបានប្រយោជន៍ពីកម្មវិធីបណ្តុះបណ្តាលរបស់អង្គការលីកាដូនៅកម្ពុជា។ លើសពីនេះទៅទៀតអង្គការលីកាដូ បានបញ្ជូនបុគ្គលិកចំនួន ៨៩នាក់ ទៅរៀនវគ្គ

បណ្តុះបណ្តាល ដែលរៀបចំនៅខាងក្រៅអង្គការក្នុងឆ្នាំ ២០០៧នេះ។ ប្រធានបទនិមួយៗមានដូចជា វគ្គប្រឹក្សាយោបល់ វគ្គជំនាញស៊ើបអង្កេត និងឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងវគ្គស្តីអំពីអារម្មណ៍របស់អតិថិជន។

សេចក្តីប្រកាសព័ត៌មានជាច្រើន និងរបាយការណ៍សង្ខេបបានចេញផ្សាយនៅក្នុងឆ្នាំ ២០០៧ ក្នុងបំណងអប់រំដល់រដ្ឋាភិបាល និងសង្គមស៊ីវិល ប្រព័ន្ធផ្សព្វផ្សាយ និងដល់សាធារណៈជន អំពីបញ្ហាច្បាប់ និងសិទ្ធិមនុស្ស។ របាយការណ៍ ទាំងនោះធ្វើឡើងក្រោមការសហការជាមួយអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ បញ្ជីសកម្មភាពទាំងនោះបានរកឃើញបន្ថែមទៀត។ បញ្ជីយោងនៃគ្រប់សកម្មភាពទាំងអស់នោះអាចរកឃើញនៅក្នុងឧបសម្ព័ន្ធ។ បញ្ជីរាយឈ្មោះខាង ក្រោមនេះមានរួមទាំងរបាយការណ៍សរុប របាយការណ៍សង្ខេបដែលបានបោះពុម្ភចេញផ្សាយដោយអង្គការលីកាដូ នៅក្នុងឆ្នាំ ២០០៧ មានដូចជា:

- *សិទ្ធិមនុស្សនៅកម្ពុជា: យុត្តិធម៌គ្មានភាពប្រាកដនិយម របាយការណ៍លីកាដូ ឆ្នាំ ២០០៧*
- *គណៈកម្មាធិការស្ត្រីកម្ពុជា: អំពើហិង្សាប្រឆាំងនារីភេទ តើច្បាប់កម្ពុជាមានការរើសអើងប្រឆាំងនារីភេទដោយរបៀបណា របាយការណ៍ ឆ្នាំ ២០០៧*
- *របាយការណ៍លីកាដូ: គំរោងសាកល្បងរបស់ការិយាល័យសិទ្ធិស្ត្រី របាយការណ៍ឆ្នាំ ២០០៧*
- *របាយការណ៍ការបង្ខំបណ្តេញចេញដោយខុសច្បាប់លើប្រពលរដ្ឋ ១០៥គ្រួសារ នៅក្រុងព្រះសីហនុ (របាយការណ៍សង្ខេប)*
- *អំពើហិង្សាលើស្ត្រីនៅកម្ពុជាឆ្នាំ ២០០៦ របាយការណ៍ខែ មីនា ឆ្នាំ ២០០៧*
- *ស្ថានភាពពន្ធនាគារនៅកម្ពុជា ឆ្នាំ ២០០៥ និង ២០០៦: ថ្ងៃមួយក្នុងជីវភាពរស់នៅជា ... (របាយការណ៍ ខែមករា ឆ្នាំ ២០០៧)*
- *ការរឹតបន្តឹងដោយគណៈមេធាវី: ការគំរាមកំហែងចំពោះសេរីភាព និងជំនួយផ្នែកច្បាប់ឯករាជ្យនៅកម្ពុជា (របាយការណ៍សង្ខេប)*
- *អត្ថបទនៃការពិតរបស់លីកាដូស្តីពីការលក់ដី និងការផ្ទេរកម្មសិទ្ធិដីដោយខុសច្បាប់នៅកំពង់ឆ្នាំង*
- *លោក ប៊ន សំណាង និង លោក សុខ សំអឿន: ទណ្ឌិតគ្មានទោសពៃរ៍រង់ចាំយុត្តិធម៌*
- *ការជុំនុំជំរះ និងសំដីរបស់ លោក ប៊ន សំណាង និង លោក សុខ សំអឿន របាយការណ៍សង្ខេប*
- *ការលុបចោលទោសប្រហារជីវិត : ពិធីសារតាមចិត្តជ្រើសរើសទី២ ជាប់នឹងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយ របាយការណ៍សង្ខេប*
- *ការរឹតបន្តឹងសិទ្ធិសេរីភាពប្រមូលផ្តុំនៅកម្ពុជា របាយការណ៍សង្ខេប ឆ្នាំ ២០០៦ (ខែមករា ឆ្នាំ ២០០៧)*


HUMAN RIGHTS IN CAMBODIA:
THE CHARADE OF JUSTICE
A LICADHO Report
December 2007
LICADHO


PRISON CONDITIONS IN CAMBODIA
2005 & 2006: ONE DAY IN THE LIFE...
My name is Daranith. I am 26 years old
and I live in a prison cell with 22 other men.
REPORT
January 2007
LICADHO


The Cambodian Committee of Women
Violence Against Women:
How Cambodian Laws
Against Women
A CAMBOW REPORT
November 2007

□□□

# ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស

អង្គការលីកាដូធ្វើការឃ្លាំមើលស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដោយធ្វើការប្រមូលបាន និងវិភាគលើព័ត៌មានទាក់ទងទៅនឹងអំពើហិង្សា រួមបញ្ចូលទាំងករណីរំលោភសេពសន្ថវៈ ការកេងប្រវ័ញ្ចផ្លូវភេទ និងការជួញដូរមនុស្ស ការធ្វើទារុណកម្មក្នុងមន្ទីរឃុំឃាំង ការសំលាប់ក្រៅប្រព័ន្ធតុលាការ ការឃុំខ្លួនខុសច្បាប់ ការបាត់ខ្លួន ការគំរាមកំហែង ការបំភិតបំភ័យ ការរឹបអូសដីធ្លី និងការបំផ្លិចបំផ្លាញទ្រព្យសម្បត្តិដោយខុសច្បាប់ ។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សជួយដល់ជនរងគ្រោះក្នុងការរៀបចំពាក្យបណ្តឹងទៅប៉ូលីស តុលាការ ឬស្ថាប័នពាក់ព័ន្ធ និងធ្វើការតស៊ូមតិសំរាប់ករណីរបស់គេដើម្បីជំរុញការស៊ើបអង្កេត និងធ្វើការដោះស្រាយតាមផ្លូវច្បាប់ ។ អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៅការិយាល័យភ្នំពេញ និងការិយាល័យតាមខេត្ត បានធ្វើការឃ្លាំមើលជាទៀងទាត់នៅក្នុង ១៨ពន្ធនាគារ និងការិយាល័យកណ្តាល ដោយធ្វើការកត់ត្រាព័ត៌មានបន្ថែមអំពីស្ថានភាពអ្នកទោស និងអំពើហិង្សាលើសិទ្ធិមនុស្សដែលបានកើតឡើងក្នុងពេលឃុំខ្លួន ។




## គោលបំណង

- ការកត់សំគាល់ទៅលើការរំលោភសិទ្ធិមនុស្ស និងអោយអាជ្ញាធរបានដឹងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ។
- ការបង្កើតឡើងចំណុចសំខាន់ៗដោយការរំលោភសិទ្ធិមនុស្សត្រូវបានគេបង្ហាញចេញកត់ត្រាទុកជាឯកសារការរក្សាទុកការស៊ើបអង្កេត និងកែតំរូវកំហុសដែលបានរកឃើញ
- ការយកចិត្តទុកដាក់ជាពិសេសលើការរំលោភសិទ្ធិមនុស្ស ដែលជះឥទ្ធិពលដោយផ្ទាល់ដល់សមាជិកងាយរងគ្រោះនៅក្នុងសង្គម ។
- ការបង្កើត និងអនុវត្តន៏យុទ្ធសាស្រ្តដ៏មានប្រសិទ្ធិភាពដើម្បីផ្សារភ្ជាប់ជាមួយការអនុវត្តន៏ច្បាប់របស់អាជ្ញាធរជំនួសមុខអោយជនរងគ្រោះនិងដើម្បីពង្រឹងជំនាញនិងដើម្បីការពាររាល់អំពើរំលោភបំពាននៅពេលខាងមុខ ។
- ការបង្កើតតំបន់ជំនាញអោយជាក់លាក់ក្នុងការចំណាត់ប្រភេទសិទ្ធិមនុស្សដែលនោះជាការព្រួយបារម្ភជាពិសេសចំពោះអង្គការលីកាដូ ដែលមានដូចជាៈ ការសំលាប់ក្រៅប្រព័ន្ធច្បាប់ ការធ្វើទារុណកម្មនៅក្នុងមន្ទីរឃុំឃាំង

ប៉ូលីស ការឃុំខ្លួនខុសច្បាប់ ការបាត់ខ្លួន ការចាប់ជំរិត ការគំរាមកំហែង ការបំភិតបំភ័យ ការរឹបអូសដីធ្លី ការជួញដូរមនុស្ស ការរំលោភសេពសន្ថវៈ និងការរំលោភបំពានផ្លូវភេទលើស្ត្រី និងកុមារ ។

- ការប្រមូល និងរក្សាទុកនៅឯកសារ និងទិន្នន័យសំរាប់ស្រាវជ្រាវវិភាគទៅលើករណីរំលោភសិទ្ធិមនុស្សរួមទាំងការភ្ជាប់ធនធានព័ត៌មានថ្នាក់ជាតិ និងអន្តរជាតិសំរាប់ធ្វើការតស៊ូមតិទាក់ទងនឹងផ្លូវច្បាប់បញ្ហានៅក្នុងសង្គម
- ការរក្សានូវអ្នកជំនាញផ្នែកច្បាប់នៅក្នុងអង្គការ និងទទួលអ្នកការពារច្បាប់ពីអង្គការដទៃទៀត ។
- ការបង្កើតឱ្យមានគុណភាពល្អនូវរាល់របាយការណ៍ទាក់ទាញមតិគាំទ្រ សេចក្តីថ្លែងការណ៍ របាយការណ៍សង្ខេបខ្លីៗ និងការឆ្លើយតបរបស់អង្គការលីកាដូ គណៈកម្មាធិការប្រព្រឹត្តិកម្មនៃអង្គការ-សហគមការពារ សិទ្ធិមនុស្សកម្ពុជា គណៈកម្មាធិការស្ត្រីកម្ពុជា ក្រុមអ្នកការពារសិទ្ធិលំនៅឋាន វេទិការអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា និងសន្និសញ្ញាអង្គការមិនមែនរដ្ឋាភិបាលអំពីសិទ្ធិកុមារដែលបានពិចារណាលើករណីធ្ងន់ធ្ងរ ឬទំរង់នៃការរំលោភបំពាន និងការកែប្រែជាបន្ទាន់ និងរកវិធានការទប់ស្កាត់ជាមុន ។

## លទ្ធផលសំរេចបាន

ក្នុងឆ្នាំ២០០៧ សកម្មភាពសំខាន់ៗនៃការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សបានធ្វើការបែងចែកជាបីផ្នែកមានៈ ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស កម្មវិធីស្រាវជ្រាវពន្ធនាគារ និងកម្មវិធីមេធាវីការពារសិទ្ធិមនុស្ស (HRLP) ។

ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្សធ្វើការជាចំបងលើសកម្មភាពឃ្លាំមើល និងការស្រាវជ្រាវលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយមន្ត្រីរដ្ឋាភិបាល ។ កម្មវិធីស្រាវជ្រាវពន្ធនាគារធ្វើការឃ្លាំមើលពន្ធនាគារ ១៨ ក្នុងចំនោម ២៦ ពន្ធនាគារទូទាំងខេត្ត-ក្រុង ក្នុងប្រទេសកម្ពុជា ដោយធ្វើការទៅលើការរំលោភសិទ្ធិមនុស្ស ។ អ្នកស្រាវជ្រាវពន្ធនាគារក៏បានធ្វើការសហការជាមួយការិយាល័យពេទ្យរបស់អង្គការលីកាដូ ដែលបានចុះត្រួតពិនិត្យ និងព្យាបាលអ្នកទោសក្នុង ១២ ពន្ធនាគារ ។ កម្មវិធីអ្នកច្បាប់ការពារសិទ្ធិមនុស្សបានបង្កើតក្រុមថ្មីមួយនៅក្នុងឆ្នាំ ២០០៦ ដើម្បីផ្តល់ជំនួយផ្នែកច្បាប់ និងធ្វើជាតំណាងដើម្បីជ្រើសរើសចំនួននៃប្រភេទ ករណីរំលោភសិទ្ធិមនុស្ស ។

### *ការិយាល័យឃ្លាំមើលសិទ្ធិមនុស្ស*

នៅក្នុងឆ្នាំ ២០០៧ ការិយាល័យឃ្លាំមើលសិទ្ធិមនុស្សបានស៊ើបអង្កេតសរុបមានចំនួន ៣២៣ ករណី ក្នុងនោះមានជនរងគ្រោះដែលពាក់ព័ន្ធការរំលោភបំពានលើសិទ្ធិមនុស្សចំនួន ៩៥៤២ នាក់ ។




ពេញមួយឆ្នាំ ២០០៧ មានជនរងគ្រោះជាច្រើននៅក្នុងបទល្មើស និមួយៗដោយករណីការវិវាទដីធ្លី។ ករណីវិវាទដីធ្លីគឺជា ករណីដែលធ្ងន់ធ្ងរបំផុត ដែលវាបានប៉ះពាល់ទៅការចិញ្ចឹមជីវិតរបស់គ្រួសារ និងសហគមន៏ទាំងមូល។ អ្នកគ្មានដីនៅ ប្រទេសកម្ពុជាគឺធ្លាក់ក្នុងភាពក្រីក្រជាបន្តបន្ទាប់ផ្លាស់ប្តូរទីលំនៅទៅទីក្រុង បែកបាក់គ្រួសារ និងបំផ្លិចបំផ្លាញសហគមន៏ ជាពិសេសខ្វះអាហារូបត្ថម្ភ សេចក្តីអត់ឃ្លាន និងសេចក្តីស្លាប់។

## ករណីសិក្សា : ការរំលោភដីធ្លីដោយមេឃុំ នៅឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ

តាំងពីឆ្នាំ១៩៨២ មានពលរដ្ឋជាច្រើនរស់នៅភូមិកុចទីទុយ និងភូមិពពាយ ឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ បានមករស់នៅលើដីរបស់ខ្លួនដោយគ្មានបញ្ហាអ្វីទេ។

នៅក្នុងឆ្នាំ២០០២ មានអ្នកភូមិរស់នៅក្នុងម្តុំត្រពាំងគុមផ្អែង (នៅក្នុងភូមិកុចទីទុយ) បានផ្អាកធ្វើស្រែចំការដោយសារតែគោក្របីរបស់ពួកគាត់ត្រូវបានគេលួចចាប់ទុក និងខ្លះត្រូវគេសំលាប់។ បន្ទាប់មកនៅឆ្នាំ២០០៦ ប្រជាពលរដ្ឋបានទៅធ្វើស្រែចំការនៅលើដីរបស់ពួកគាត់វិញតាមធម្មតា។ លោក ប៊ុត ក្លុក អាយុ៤៨ឆ្នាំ និងលោក មែន ផាត អាយុ៥៤ឆ្នាំ មេឃុំទ្រា ស្រុកស្ទោង ខេត្តកំពង់ធំ បានហាមឃាត់ប្រជាពលរដ្ឋចំនួន ៣៥គ្រួសារមិនអោយពួកគាត់ធ្វើស្រែចំការលើដីរបស់ពួកគាត់ ហើយគេបានផ្ទេរដីអោយពួកគាត់ទាំង៣៥គ្រួសារទៅឃុំទ្រាវិញ។

នៅថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៧ អង្គការលីកាដូបានស្នើរសុំទៅលោក ហេង ជាប្រធានគណៈកម្មាធិការដោះស្រាយវិវាទដីធ្លីនៅស្រុកស្ទោង ខេត្តកំពងធំ ដើម្បីចូលរួមដោះស្រាយបញ្ហានេះ។

នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០៧ អ្នកឃ្លាំមើលសិទ្ធិមនុស្សលីកាដូ បានជួបជាមួយលោកហេង ហើយបានបញ្ជាក់ថា កិច្ចចរចាររវាងសហគមន៏ និងអាជ្ញាធរគឺមានសារៈសំខាន់។ ជាលទ្ធផល លោកមេឃុំបានមានប្រសាសន៏ថាប្រជាពលរដ្ឋបានរស់នៅលើដីមានរយៈពេលយូរណាស់មកហើយ ហើយគាត់បានប្រគល់ដីអោយសហគមន៏វិញ។

## *កម្មវិធីស្រាវជ្រាវពន្ធនាគារ*

នៅក្នុងឆ្នាំ២០០៧ កម្មវិធីពន្ធនាគារបានសម្ភាសន៍អ្នកទោសចំនួន២.៥៥៦ នាក់ (អ្នកទោសស្ត្រីចំនួន២០៨ នាក់) ទាំងពិរុទ្ធជន និងទណ្ឌិត។ ក្នុងការធ្វើសម្ភាសន៍អ្នកទោសចំនួន១៥៥នាក់ និងអ្នកទោស្ត្រី៩នាក់ ត្រូវបានគេរាយការណ៍ថាពួកគេត្រូវគេធ្វើទារុណកម្ម (ទារុណកម្មក្នុងមន្ទីរឃុំឃាំងប៉ូលីសចំនួន ១២៥ នាក់ និងក្នុងពន្ធនាគារចំនួន២៩នាក់)។ អ្នកស្រាវជ្រាវពន្ធនាគាររបស់អង្គការលីកាដូចុះសួរសុខទុកអ្នកទោសមួយដងក្នុងមួយសប្តាហ៍ដើម្បីសម្ភាសន៍អ្នកទោស។ ការធ្វើសម្ភាសន៍ត្រូវចំណាយពេលពី២-៣ម៉ោង ដោយអាចសម្ភាសន៍បានអ្នកទោសពី២-៤ នាក់។ អ្នកស្រាវជ្រាវពន្ធនាគារបានប្រើទំរង់សំណួរដែលមានស្រាប់សំរាប់សួរអ្នកទោសអំពីការព្យាបាល ស្ថានភាពរស់នៅក្នុងពន្ធនាគារ ការធ្វើបណ្តឹង ព័ត៌មានផ្នែកច្បាប់ និងព័ត៌មានសំខាន់ៗផ្សេងទៀត។

## *កម្មវិធីមេធាវីការពារសិទ្ធិមនុស្ស*

ជាផ្នែកមួយនៃការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស កម្មវិធីមេធាវីត្រូវបានបង្កើតឡើងនៅក្នុងឆ្នាំ ២០០៦ ដើម្បីឆ្លើយតបនឹងការកើនឡើងតំរូវការជំនួយផ្នែកច្បាប់និងអ្នកតំណាងច្បាប់អោយជនរងគ្រោះដោយករណីរំលោភសិទ្ធិមនុស្ស។ ក្រុមមេធាវីចំនួន៥នាក់ និងទីប្រឹក្សាម្នាក់កំពុងធ្វើការលើកម្មវិធីនេះ។ ពួកគេជាអ្នកតំណាងផ្នែកច្បាប់ការពារជនរងគ្រោះដោយការរំលោភបំពាន អំពើរំលោភសេពសន្ថវៈ អំពើជួញដូរមនុស្ស ការគំរាមកំហែងលើអ្នកការពារសិទ្ធិមនុស្ស និងករណីរំលោភយកដីធ្លីនៅគ្រប់ការិយាល័យទាំង១២។ មានករណីជាង ៣៨ ត្រូវបានកម្មវិធីមេធាវីការពារសិទ្ធិមនុស្សទទួលដោះស្រាយនៅក្នុងឆ្នាំ២០០៧។ ករណីទាំងអស់នោះត្រូវបានបញ្ជូនទៅកម្មវិធីការពារសិទ្ធិមនុស្ស បន្ទាប់ពីករណីទាំងនោះត្រូវបានស្រាវជ្រាវ និងផ្តល់អនុសាសន៍ដោយអ្នកឃ្លាំមើលរបស់ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងការិយាល័យសិទ្ធិស្ត្រី។

### <u>លទ្ធផល</u>

- ជនរងគ្រោះមួយចំនួនត្រូវបានអនុញ្ញាតដើម្បីស្វែងរកផលប្រយោជន៍ទៅលើផ្នែកច្បាប់ និងជួយគាំទ្រជនរងគ្រោះនៅក្នុងសហគមន៍របស់ពួកគេ។

- បញ្ហាបន្ទាន់ត្រូវបានកំណត់ ធ្វើសហប្រតិបត្តិការ និងជួយឧបត្ថមគ្រាំទ្រទៅលើសិទ្ធិមនុស្ស នៅតាមសហគមន៍របស់ពួកគាត់។ លីកាដូ បានចូលរួមសកម្មភាពដោយផ្ទាល់នៅក្នុងការឆ្លើយតបលើរាល់ការឃុំខ្លួនអ្នកការពារសិទ្ធិមនុស្ស។

- សហគមន៍បានចូលរួម និងខំប្រឹងប្រែងធ្វើការទាក់ទាញមតិគាំទ្រយ៉ាងពេញទំហឹង ដើម្បីពង្រឹងអំណាចដល់ជនរងគ្រោះ និងអ្នកទាក់ទាញមតិគាំទ្រ។

- អ្នកស្រាវជ្រាវពន្ធនាគារនៅតែបន្តធ្វើការទៅលើការឃ្លាំមើល និងការស៊ើបអង្កេតនៅ ១៨ ពន្ធនាគារក្នុងចំនោមពន្ធនាគារ ២៦ ទូទាំងប្រទេស។ ការចុះសួរសុខទុក្ខអ្នកទោសក្នុងពន្ធនាគារនេះអាចអោយអ្នកស្រាវជ្រាវពន្ធនាគារ និងបុគ្គលិកពេទ្យ អាចដឹងនិងធានាបានថាអ្នកទោសទាំងនោះទទួលបានអ្នកតំណាងផ្នែកច្បាប់ ទទួលបានសុខភាពមូលដ្ឋាន ដែលអាចអោយពួកគាត់ធ្វើការផ្លាស់ប្តូរ និងកែប្រែនៅពេលដែលសិទ្ធិរបស់ពួកគាត់ត្រូវគេរំលោភបំពាន។

- ជំនួយបន្ទាន់ត្រូវផ្តល់ដល់ជនរងគ្រោះនៃការរំលោភបំពាន រួមទាំងការផ្តល់អាហារបន្ថែម សំភារៈចំបាច់ និងការពិនិត្យព្យាបាល។

□□□

# ការិយាល័យសិទ្ធិស្ត្រី



លីកាដូ ដើរតួនាទីយ៉ាងសកម្មក្នុងការលើកកំពស់ការយល់ដឹងអំពីយេនឌ័រ និងសិទ្ធិស្ត្រីតាមរយៈវគ្គហ្វឹកហ្វឺនសិក្ខាសាលាដែលបានរៀបចំធ្វើឡើងនៅទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តដែលបានជ្រើសរើសខ្លះទៀត សំរាប់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល អ្នកដឹកនាំសហគមន៍ អ្នកបំរើការងារសង្គមស៊ីវិល ប៉ូលិស និងកងកំលាំងប្រដាប់អាវុធផ្សេងៗទៀត ។ លីកាដូក៏បានផ្តល់សេវាកម្មបន្ថែមទៀតរួមមានទាំងតំណាងផ្នែកច្បាប់ ការប្រឹក្សា យោបល់ ការថែទាំសុខភាព និងផ្តល់ជំរកស្នាក់នៅដល់ស្ត្រីជាជនរងគ្រោះដោយសារការរំលោភសេពសន្ថវៈ ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារ ។ លីកាដូ ធ្វើការជាមួយគណៈកម្មាធិការក្នុងស្រុក និងអន្តរជាតិប្រយោជន៍ ដើម្បីលើកកំពស់ និងទាក់ទាញមតិគាំទ្រសិទ្ធិស្ត្រី ។

<u>គោលបំណង</u>

- រកឱ្យឃើញនូវការរំលោភបំពានលើសិទ្ធិស្ត្រី ជាពិសេសជនរងគ្រោះដោយសារការចាប់រំលោភសេពសន្ថវៈ ការជួញដូរ និងអំពើហិង្សាក្នុងគ្រួសារ ព្រមទាំងផ្តល់ចំណេះដឹងអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា ។
- ផ្តួចផ្តើមគំនិត និងធ្វើកិច្ចសហប្រតិការជាមួយអង្គការដៃគូជាច្រើនទៀតដូចជា CWCC, GAD, PADV និង CAMBOW (ជាសមាគមន៍អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន ៣៦ ដែលកំពុងធ្វើការ ដើម្បីលើកកំពស់សិទ្ធិស្ត្រី) ដើម្បីបង្កើនផលប៉ះពាល់ឱ្យមានប្រសិទ្ធភាពខ្ពស់ ។
- ដើម្បីទទួលបាននូវការទទួលស្គាល់ និងតំណាងរបស់ស្ត្រីដោយពេញលេញ ស្មើរភាពគ្នា និងយុត្តិធម៌នៅក្នុងគ្រប់ស្រទាប់វណ្ណៈទាំងអស់ ដោយស្របទៅតាមទិន្ន័យប្រជាសាស្ត្រ និងការរួមចំណែកនៃសាច់ញាតិរបស់ពួកគេ ព្រមទាំងសមាជិករបស់ក្រុមនិមួយៗផងដែរ ។
- ដើម្បីប្រឆាំងនឹងការរើសអើងពីសំណាក់បុរស និងក្មេងប្រុស រួមទាំងទំនៀមទំលាប់ប្រពៃណី និងដើម្បីលើកកំពស់សមភាពយេនឌ័រ ។

- ដើម្បីផ្តល់ជំនួយផ្នែកសម្ភារៈ ការពារ និងផ្តល់ការគាំទ្រជាពិសេស និងតាមដាន រួមទាំងតំណាងផ្នែកច្បាប់ឱ្យស្ត្រីជាពិសេសជនរងគ្រោះដោយការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារ ឬការរើសអើងណាដែលប៉ះពាល់ដល់សិទ្ធិរបស់ពួកគេ។
- ធ្វើការទាក់ទាញមតិគាំទ្រដើម្បីឱ្យមានកំណែទំរង់ច្បាប់ និងសង្គម ដែលប៉ះពាល់ដល់ស្ត្រីនៅកម្ពុជា ជាពិសេសទៅលើការជួញដូរមនុស្ស អំពើហិង្សាក្នុងគ្រួសារ និងការរំលោភសេពសន្ថវៈ។

## លទ្ធផលសំរេចបាន

សកម្មភាពជាចំបងរបស់ការិយាល័យសិទ្ធិស្ត្រីនៅក្នុងឆ្នាំ ២០០៧ គឺ

- ឃ្លាំមើល និងស៊ើបអង្កេតទៅលើករណីដែលសិទ្ធិស្ត្រីត្រូវបានរំលោភបំពាន
- ធ្វើការអប់រំដល់ស្ត្រី និងអជ្ញាធរមូលដ្ឋានអំពីសិទ្ធិស្ត្រី និងច្បាប់ផ្សេងៗដែលទាក់ទងនឹងសិទ្ធិស្ត្រីនៅកម្ពុជា
- ធ្វើការទាក់ទាញមតិគាំទ្រដើម្បីលើកកំពស់បុព្វហេតុស្ត្រីកម្ពុជា
- ផ្តល់វគ្គហ្វឹកហ្វឺនដល់បុគ្គលិកដើម្បីបង្កើនគុណភាពការងារ ដែលបានរៀបចំធ្វើឡើងដោយការិយាល័យសិទ្ធិស្ត្រី
- ការពាក់ព័ន្ធរបស់អ្នកហាត់ការបរទេសដើម្បីរួមចំណែកក្នុងការលើកកំពស់ការយល់ដឹងជាសាកលអំពីស្ថានភាពស្ត្រីកម្ពុជា និង
- ធ្វើការផ្លាស់ប្តូរបន្ទប់ការិយាល័យ ដើម្បីបង្កើតបរិយាកាសអោយកាន់តែមានភាពស្និតស្នាលសំរាប់អតិថិជន។

### *ការឃ្លាំមើល និងការស៊ើបអង្កេត*

នៅឆ្នាំ ២០០៧ អ្នកឃ្លាំមើលការរំលោភសិទ្ធិស្ត្រីនៃការិយាល័យសិទ្ធិស្ត្រីក្រុងភ្នំពេញ និងអ្នកឃ្លាំមើលការរំលោភសិទ្ធិនៃការិយាល័យលីកាដូតាមបណ្តាខេត្តបានស៊ើបអង្កេតករណីរំលោភសិទ្ធិស្ត្រីសរុបចំនួន៣០២ករណី។ នៅក្នុងនោះមានជនរងគ្រោះចំនួន៣១២ នាក់ និងជនល្មើសចំនួន៣៣៣ នាក់។ ករណីទាំងនោះទាក់ទងនឹងអំពើហិង្សាក្នុងគ្រួសារ ការចាប់រំលោភសេពសន្ថវៈ និងការជួញដូរមនុស្សក្នុងគោលបំណងកេងប្រវ័ញ្ចផ្លូវភេទ។

**ករណីរំលោភសិទ្ធិស្ត្រីដែលការិយាល័យសិទ្ធិស្ត្រីបានទទួលក្នុងឆ្នាំ២០០៧**




យោងតាមស្ថិតិខាងលើនេះ បង្ហាញយ៉ាងច្បាស់ថា ការរាយការណ៍ និងការស៊ើបអង្កេតអំពីអំពើហិង្សាក្នុងគ្រួសារបានកើនឡើងនូវអត្រាយ៉ាងខ្ពស់ បើប្រៀបធៀបទៅនឹងប្រភេទករណីផ្សេងៗទៀតនៅក្នុងឆ្នាំ ២០០៧។ អំពើហិង្សាក្នុង គ្រួសារបានកើនឡើងរហូតដល់ទៅ៦៩ ភាគរយ នៅឆ្នាំនេះ។

បើប្រៀបធៀបទៅនឹងឆ្នាំ ២០០៦ ចំនួនសរុបនៃករណីដែលបានរាយការណ៍បានថយចុះពី ៣១២ មក ៣០២ ប៉ុន្តែ ការធ្លាក់ចុះនេះទំនងដោយសារតែកម្រិតបុគ្គលិក និងខ្វះបុគ្គលិកជំនាញនៅតាមខេត្ត មិនមែនធ្លាក់ចុះនៃប្រភេទករណីនោះទេ។ ការិយាល័យសិទ្ធិស្ត្រីដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយផ្តល់ប្រឹក្សាផ្នែកច្បាប់ និងព័ត៌មានដែលទាក់ទងទៅនឹងនិតិវិធីច្បាប់ទៅឱ្យអតិថិជន។

តារាងខាងក្រោមនេះបង្ហាញពីការប្រៀបធៀបនៃចំនួនអតិថិជន ដែលបានទទួលសេវាប្រឹក្សាផ្នែកច្បាប់ពីការិយាល័យសិទ្ធិស្ត្រី និងការិយាល័យនៅតាមខេត្ត ពីឆ្នាំ ២០០៥ ដល់ ២០០៧

**ការផ្តល់សេវាប្រឹក្សាផ្នែកច្បាប់ពីឆ្នាំ២០០៥ ដល់ ២០០៧**

| **ឆ្នាំ** | **២០០៥** | **២០០៦** | **២០០៧** |
|---|---|---|---|
| អំពើហិង្សាក្នុងគ្រួសារ | ១៧២ | ២៣៣ | ៣៨៥ |
| រំលោភសេពសន្ថវៈ | ៩ | ១៧ | ៣៦ |
| ការជួញដូរមនុស្ស | ៤ | ០ | ៦ |
| **សរុប** | **១៨៥** | **២៥០** | **៤២៧** |

### *ការផ្ដល់ជំនួយជនរងគ្រោះ*

ការិយាល័យសិទ្ធិស្ត្រី ក៏ផ្ដល់ជំនួយផ្នែកសម្ភារៈដល់អតិថិជនដែលត្រូវការយ៉ាងពិតប្រាកដ ។ ជំនួយទាំងនោះរួមមាន ការផ្ដល់សម្ភារៈប្រើប្រាស់ ដូចជា មុង អង្ករ ប្រេងឆា ធុងទឹក ថ្លៃធ្វើដំណើរ និងថ្នាំដុសធ្មេញ។ ចំនួនសរុបនៃអតិថិជន ៥៦នាក់ បានទទួលសេវាកម្មទាំងនេះ ហើយអតិថិជន ៤៣នាក់ ក្នុងចំណោមអតិថិជន៥៦នាក់ បានរាយការណ៍អំពីការប្រើអំពើហិង្សាក្នុងគ្រួសារ ។

### *គំរោងសាកល្បងទៅផ្នែកអប់រំ*

ការិយាល័យសិទ្ធិស្ត្រី បានបន្តគំរោងសាកល្បងរបស់ខ្លួននៅក្នុងឆ្នាំ ២០០៧ ដែលមានគោលបំណងអប់រំស្ត្រី (ស្ត្រីដែលជ្រើសរើស "ជនបង្គោល") អជ្ញាធរមូលដ្ឋាន និងសហគមន៍ទូទៅអំពីសិទ្ធិស្ត្រី និងច្បាប់នានាដែលទាក់ទងនឹងសិទ្ធិស្ត្រីកម្ពុជា។ គំរោងនេះធ្វើនៅក្នុងខេត្តកណ្ដាល និងបានចាប់ផ្ដើមគំរោងសាកល្បងនេះ ដល់ខេត្តកំពត និងខេត្តកំពង់ធំ នៅខែកក្កដា។ គោលបំណងនៃវគ្គបណ្ដុះបណ្ដាលដែលផ្ដោតលើស្ត្រីគឺៈ

- ដើម្បីបង្ហាត់បង្ហាញ និងផ្ដល់ការគាំទ្រដល់ជនបង្គោលដើម្បីអប់រំប្រជាជននៅក្នុងសហគមន៍របស់ពួកគេ អំពីអំពើហិង្សាប្រឆាំងនឹងនារីភេទតាមមធ្យោបាយក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ ។
- ដើម្បីបង្កើតបណ្ដាញគាំទ្រ និងអប់រំជាមួយស្ត្រីនៅក្នុងសហគមន៍ទាំងនេះ និង
- ដើម្បីធ្វើអោយប្រសើរឡើងនូវការយល់ដឹង និងអនុវត្តវិធីសាស្ត្របញ្ចុះបញ្ចូល និងធ្វើការជាមួយអជ្ញាធរមូលដ្ឋានដូចជា ប៉ូលិស និងមេឃុំក្នុងករណីអំពើហិង្សាប្រឆាំងនឹងនារីភេទនៅក្នុងសហគមន៍ ។

ថ្មីៗនេះ ការិយាល័យសិទ្ធិស្ត្រីបានរៀបចំវគ្គតាមដានប្រចាំខែចំនួនពីរវគ្គជាមួយនឹងជនបង្គោល និងបន្តវគ្គសិក្សាទាំងនេះនៅ ឆ្នាំ២០០៨ទៀត ។

នៅក្នុងកម្មវិធីនេះ មានអជ្ញាធរមូលដ្ឋានចំនួន ៤៧ នាក់ ដែលក្នុងនោះមានប៉ូលិស មេភូមិ មេឃុំ និងសមាជិកផ្នែកច្បាប់ ក៏បានអញ្ជើញចូលរួមផងដែរ ។ វគ្គហ្វឹកហ្វឺកសំរាប់ក្រុមនេះ គ្របដណ្ដប់លើប្រធានបទដូចតទៅៈ

- យល់ដឹងពីនិយមន័យបញ្ហាអំពើហិង្សាក្នុងប្រឆាំងនឹងនារីភេទទាំងការអនុវត្តជាក់ស្ដែង និងផ្នែកច្បាប់ព្រមទាំងច្បាប់ដែលមានមានស្រាប់ពាក់ព័ន្ធទាំងឡាយ ។

- ផលប៉ះពាល់ចិត្តសង្គមដោយប្រើអំពើហិង្សាទៅលើជនរងគ្រោះនិងវិធីសាស្ត្រជាក់ស្តែងដើម្បីទប់ស្កាត់ករណីខាងលើនេះ
- ការពារសិទ្ធិរបស់ជនរងគ្រោះនៅក្នុងដំណើរការច្បាប់ ។

## *ឧបករណ៍ទាក់ទាញមតិគាំទ្រ*

ការិយាល័យសិទ្ធិស្ត្រី (ដោយមានជំនួយពីបុគ្គលិកការិយាល័យ ទាក់ទាញមតិគាំទ្រ ឯកសារ និងធនធានព័ត៌មាន របស់លីកាដូ) បានរៀបចំបង្កើតកូនសៀវភៅរឿងបែបរូបភាពមួយមានចំនងជើងថា "**ជីវិតក្នុងភាពអន្ធកាល**" ។ គោលបំណងរបស់សៀវភៅនេះដើម្បីពិភាក្សាអំពីបញ្ហាអំពើហិង្សាក្នុងគ្រួសារនិងអំពីរបៀបដែលបញ្ហានេះបានជះឥទ្ធិពលទៅដល់ជីវិតគ្រួសារមួយនៅក្នុងប្រទេសកម្ពុជា ដែលនាំឱ្យមានការរំលោភសេពសន្ថវៈ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ មនុស្សឃាដ និងការជួញដូរមនុស្សដើម្បីកេងប្រវ័ញ្ចផ្លូវភេទ ។ កូនសៀវភៅនេះត្រូវបានរៀបចំជាកូនសៀវភៅមានរូបភាព ដែលមានគោលដៅសំរាប់សមាជិកសហគមន៍ដែលមិនចេះអក្សរ ។ ថ្មីៗនេះកូនសៀវភៅរូបភាពនេះកំពុងផលិតហើយនឹងត្រូវចេញផ្សាយដើម្បីចែកជូនសាធារណជននៅក្នុងខែមិនា/មេសា ឆ្នាំ ២០០៨ ខាងមុខនេះ ។




លីកាដូ ក៏បានចែកជូនផ្ទាំងរូបភាពដែលមានសារអប់រំ ស្តីអំពើហិង្សាក្នុងគ្រួសារទៅដល់សិក្ខាកាមចូលរួមទាំងអស់នៅក្នុងគម្រោងសាកល្បងនេះ ។

## *ការទាក់ទាញមតិគាំទ្រ*

លោកស្រី វេជ្ជបណ្ឌិត ពុង ឈីវកេក ប្រធានអង្គការលីកាដូ នៅតែជាប្រធាន គណៈកម្មការស្ត្រីកម្ពុជា (ជាសម្ព័ន្ធអង្គការដែលមានសមាជិកចំនួន ៣៦ ធ្វើការដើម្បីលើកកំពស់បុព្វហេតុស្ត្រីនៅកម្ពុជា) ។ គណៈកម្មការស្ត្រីកម្ពុជាមានអង្គប្រជុំជាផ្លូវការចំនួនបួនលើកហើយនៅក្នុងឆ្នាំនេះ ហើយការិយាល័យសិទ្ធិស្ត្រី បានជួយអង្គការស្ត្រីកម្ពុជា នៅក្នុងសកម្មភាពរបស់ខ្លួនជាច្រើននៅឆ្នាំ២០០៧ ។ សកម្មភាពនេះរួមមាន ការរៀបចំអង្គប្រជុំរបស់សមាជិកអង្គការក្រៅរដ្ឋាភិបាលនៅការិយាល័យលីកាដូ និងសំរបសំរួលកម្មវិធីយុទ្ធនាការថ្ងៃ ១៦ ប្រចាំឆ្នាំដើម្បីអប់រំដល់សាធារណៈជនអំពីចំណុចជាក់លាក់នៃច្បាប់ស្តីពីអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ។

នៅថ្ងៃទី ៨ មិនា ឆ្នាំ ២០០៧ ការិយាល័យសិទ្ធិស្ត្រីបានរៀបចំប្រារព្ធទិវា ដែលមានកិច្ចសហប្រតិបត្តិការ




ជាមួយម្ចាស់ជំនួយ ក្នុងគោលបំណងដើម្បីទទួលស្គាល់ទិវាសិទ្ធិនារីអន្តរជាតិ។ ឆ្នាំនេះលីកាដូបានសំរេចចិត្តធ្វើសេចក្តី ព្រៀង និងចែកចាយរបាយការប្រចាំឆ្នាំរបស់ខ្លួនស្តីអំពីអំពើហិង្សាប្រឆាំង នឹងស្ត្រី នៅថ្នាក់តំបន់ ថ្នាក់ជាតិ និងអន្តរជាតិ។ ជាមួយគ្នានោះដែរ កម្មវិធីវិទ្យុខ្លីៗក៏ត្រូវបានចាក់ផ្សាយនៅក្នុងប្រទេសកម្ពុជា ដើម្បីធានានូវការយល់ដឹងអោយកាន់តែប្រសើរឡើងអំពីបញ្ហាដែលសំខាន់នៅក្នុងរបាយការណ៍នេះ។ ជាទីបញ្ចប់នេះ ជាមួយនឹងការ ចូលរួមរបស់សមាជិកគណៈកម្មាធិការស្ត្រីកម្ពុជា និងក្រុមការងារផ្សេងៗទៀតរបស់អង្គការក្រៅរដ្ឋាភិបាល លីកាដូបានចែកម្ហូបអាហារ និងសម្ភារៈសំខាន់ៗ ទៅដល់អ្នកទោសស្ត្រីនៅក្នុងពន្ធគារចំនួន ១៥ ទូទាំងប្រទេស។

### ***អ្នកហាត់ការងារ***

នៅក្នុងឆ្នាំ ២០០៧ នៅក្រោមភាពជាដៃគូរវាងអង្គការ លីកាដូ និង សាកលវិទ្យាល័យ Quebec នៅក្នុងទីក្រុង Montreal លីកាដូបាន ទទួលអ្នកហាត់ការងារចំនួន ៩ នាក់ ពីសាកលវិទ្យាល័យ Quebec នៅក្នុងទីក្រុង Montreal រួមមានទាំងនិស្សិតម្នាក់ដែលបានហាត់ការងារ ២ លើករួចមកហើយ។ អ្នកហាត់ការងារទាំងអស់បានជួយការងារដែលទាក់ទងនឹងការទាក់ទាញមតិគាំទ្រ និងគំរោងអប់រំស្តីអំពីបញ្ហាអំពើហិង្សាប្រឆាំងនារីភេទ។ ការហាត់ការងារនីមួយៗមានរយៈ ពេល៣ខែ។

### ***វគ្គបណ្តុះបណ្តាល***

ការិយាល័យសិទ្ធិស្ត្រី បានចូលរួមវគ្គបណ្តុះបណ្តាលមួយចំនួនដែលបានរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាល និងគ្រូបណ្តុះបណ្តាលផ្សេងៗជាច្រើននៅក្នុងឆ្នាំ ២០០៧។ បុគ្គលិក ២ នាក់របស់ការិយាល័យសិទ្ធិស្ត្រីក៏បានចូលរួមវគ្គសិក្សាភាសាអង់គ្លេសនៅមជ្ឈមណ្ឌលភាសាអង់គ្លេសអូស្ត្រាលី (ACE) ពីថ្ងៃទី២៦ ខែកញ្ញា ដល់ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧។ បុគ្គលិកទាំង ២ នាក់នេះបានសិក្សារយៈពេលមួយត្រីមាសនៅឆ្នាំ២០០៧។

### ***ការផ្លាស់ប្តូរការិយាល័យ***

នៅខែមេសា ២០០៧ អ្នកឃ្លាំមើលរបស់ការិយាល័យសិទ្ធិស្ត្រីបានប្តូរការិយាល័យរបស់ខ្លួនទៅនៅជិតការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស និងអាចបង្កើតបន្ទប់សម្ភាសន៍កុមារីរីករាយជាប់ការិយាល័យរបស់ខ្លួន

ទៀតផង។ ការផ្លាស់ប្តូរទីតាំងថ្មីនេះមានន័យថាអ្នកឃ្លាំមើលការរំលោភសិទ្ធិស្ត្រីអាចសម្ភាសន៍អតិថិជន និងកុមារជាលក្ខណៈបុគ្គល និងមានមានផាសុខភាព។

## ផលប៉ះពាល់



- ទាំងជនរងគ្រោះ និងជនងាយរងគ្រោះដោយការរំលោភ បានទទួលព័ត៌មានកាន់តែប្រសើរឡើង អំពីសិទ្ធិរបស់ពួកគេ និងមានទំនុកចិត្តនៅក្នុងការធ្វើសេចក្តីសំរេចចិត្តដោយស្របតាមសំណងផ្នែកច្បាប់។
- អជ្ញាធរមូលដ្ឋានក៏កាន់តែមានការយល់ដឹងអំពីកាតព្វកិច្ចរបស់ខ្លួនដើម្បីការពារសិទ្ធិស្ត្រីក្រោមច្បាប់កម្ពុជា។

□□□

# ការិយាល័យសិទ្ធិកុមារ

*អ្នកបង្ហាត់ដែលមានជំនាញនៅភ្នំពេញ និងតាមបណ្តាខេត្តដែលបានជ្រើសរើសរៀបចំបើកវគ្គហ្វឹកហ្វឺនតាម បែបចូលរួមសំរាប់ឪពុកម្តាយ កុមារ អាជ្ញាធរមូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលនានាក្នុងគោលបំណងលើក ស្ទួយការយល់ដឹង និងការអនុវត្តន៏អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីសិទ្ធិកុមារ ។ បណ្តាញការពារកុមារបាន អញ្ជើញមន្ត្រីថ្នាក់ខេត្ត អាជ្ញាធរមូលដ្ឋាន ឪពុកម្តាយ និងកុមារឱ្យចូលរួមក្នុងសកម្មភាពទប់ស្កាត់ និងការពារកុមារនៅតាមមូលដ្ឋានដោយសង្កត់ធ្ងន់លើការចូលរួមរបស់កុមារដែលផ្តោតសំខាន់លើការប្រយុទ្ធប្រឆាំងទល់នឹង រាល់ទំរង់អាក្រក់បំផុតនៃពលកម្មកុមារ ។ អ្នកពិនិត្យឃ្លាំមើលការរំលោភសិទ្ធិកុមារនៅភ្នំពេញបានផ្តល់នូវសេវា ផ្នែកច្បាប់, សេវាសង្គមកិច្ច*



## <u>គោលបំណង</u>

- កំណត់នូវការរំលោភបំពានសិទ្ធិកុមារ និងថែរក្សានូវចំនេះដឹងជាធំស្ថានភាពសិទ្ធិមនុស្សនៃក្មេងនៅក្នុងប្រទេសកម្ពុជា ។
- ផ្តល់នូវសំភារៈជំនួយ ការពារ និងផ្តល់នូវការគាំទ្រយ៉ាងពិសេស រួមមានតំណាងផ្នែកច្បាប់ដល់កុមារ និងក្រុមគ្រួសាររបស់ពួកគេ ជាពិសេសគឺជនរងគ្រោះដែលរំលោភសេពសន្ថវៈ មនុស្សឃាដ និងបង្ករបួសស្នាម
- ផ្តួចផ្តើមគំនិត និងសហការជាមួយអង្គការដៃគូ និងសមាជិកសហគមន៏ ដើម្បីផ្សព្វផ្សាយសិទ្ធិកុមារក្នុងគោលបំណងដើម្បីទទួលបានលទ្ធផលរួមជាអតិបរមា ។
- ជួយសំរបសំរួលគណៈកម្មការជាតិដើម្បីកុមារកម្ពុជាឆ្ពោះទៅរកយុទ្ធសាស្រ្តដែលមានស្ថេរភាពឱ្យលើសពីព្រឹត្តិការណ៏គ្រោងទុកដើម្បីដោះស្រាយបញ្ហាសង្គមចំបងៗ និងប្រធានបទជាច្រើនដូចជាទេសចរផ្លូវភេទ និងវប្បធមិក្នុងស្រុកដែលនាំឱ្យបញ្ហាទាំងនេះនៅតែមាន ។
- ប្រឆាំងការរំលោភបំពានពលកម្មកុមារ ដោយការពារ និងកាត់បន្ថយការចូលរួមរបស់កុមារនៅក្នុងទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារដោយបង្កើននូវការយល់ដឹង និងចាត់វិធានការដោះស្រាយបញ្ហាដែលកើតមានឡើង ។

## ផលសំរេចបាន

នៅក្នុង ២០០៧ សម្មភាពចំបងៗរបស់ការការិយាល័យសិទ្ធិកុមារគឺ

- រៀបចំកម្មវិធីបណ្តុះបណ្តាល
- បង្កើត និងថែរក្សាក្រុមការការពារកុមារ
- បង្កើតសកម្មភាពទាក់ទាញមតិគាំទ្រ
- ស៊ើបអង្កេត និងជំនួយជនរងគ្រោះ

### *សិក្ខាសាលាហ្វឹកហ្វឺនបណ្តុះបណ្តាល*

ក្នុងកំឡុងឆ្នាំ២០០៧ វគ្គបណ្តុះបណ្តាលរយៈពេលពីរថ្ងៃចំនួន ២០វគ្គត្រូវបានរៀបចំឡើង និងអ្នកចូលរួមចំនួន៤៨៨ នាក់ត្រូវបានអញ្ជើញចូលរួមក្នុងវគ្គបណ្តុះបណ្តាលនេះ។ សិក្ខាសាលាទាំងនោះត្រូវបានរៀបចំឡើងនៅខេត្តជាច្រើនជុំវិញប្រទេស និងសំរបសំរួលដោយអ្នកទាក់ទាញមតិគាំទ្រនៅក្នុងការិយាល័យតាមបណ្តាខេត្ត ដែលមានការគាំទ្រពីអ្នកទាក់ទាញមតិគាំទ្រសិទ្ធកុមារកំរិតខ្ពស់ពីការិយាល័យភ្នំពេញ។

គោលបំណងនៃសិក្ខាសាលាគឺដើម្បីលើកកំពស់ការយល់ដឹងពីសិទ្ធិកុមារ ការជួញដូរកុមារ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបញ្ហាសិទ្ធិកុមារជាច្រើនទៀតទៅដល់អាជ្ញាធរមូលដ្ឋាន (រួមទាំងបុគ្គលិករដ្ឋាភិបាល) បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ឪពុកម្តាយរបស់កុមារ គ្រូបង្រៀន សិស្សានុសិស្ស និងកុមារងាយទទួលរងគ្រោះ និងកុមារស្ថិតក្នុងស្ថានភាពគ្រោះថ្នាក់។ សិក្ខាសាលនេះមានគោលបំណងដើម្បីបង្កើតក្រុមការពារកុមារ (CPG) ដែលជាបណ្តាញមន្ត្រីមូលដ្ឋាន ឪពុកម្តាយ និងកុមារដែលឃ្លាំមើលការរំលោភបំពានសិទ្ធិកុមារនៅក្នុងសហគមន៍របស់ពួកគេ។ ក្រុមការពារកុមារត្រូវបានគេរាប់បញ្ចូលទាំងមនុស្សពេញវ័យ និងកុមារ។

ជាការឆ្លើយតមទៅនឹងសំណូមពររបស់អង្គការមិនមែនរដ្ឋាភិបាលជាច្រើន ការិយាល័យសិទ្ធិកុមារបានផ្តល់វគ្គបណ្តុះបណ្តាលទៅដល់ក្រសួងសង្គមកិច្ច។

### *ក្រុមការពារកុមារ*

នៅក្នុងឆ្នាំ២០០៧ ក្រុមការពារកុមារចំនួន១២ត្រូវបានបង្កើតឡើងដោយយោងទៅតាមសេចក្តីសន្និដ្ឋានវគ្គហ្វឹកហ្វឺនបណ្តុះបណ្តាល។ ចំនួននេះបន្ថែមលើចំនួនក្រុមការពារកុមារដែលមានស្រាប់ចំនួន៦៨។ វគ្គកសាងសមត្ថភាពត្រូវបានរៀបចំឡើង សំរាប់ក្រុមការពារកុមារដែលមានស្រាប់ និងក្រុមថ្មីប្រយោជន៍ដើម្បីបង្កើនជំនាញដល់សមាជិកនៅក្នុងក្រុមដើម្បីផ្សព្វផ្សាយបន្ត។



សមាជិកពីរនាក់ពីក្រុមការពារកុមារបានចូលរួមកិច្ចប្រជុំជាច្រើន (រៀងរាល់២ខែម្តងក្នុងរយៈពេល ៦ខែដំបូង) ស្តីពីការកសាងផែនការយុទ្ធសាស្ត្រសិទ្ធិកុមារ និងការ ចូលរួមរបស់កុមារ ដែលរៀបចំដោយគណៈកម្មការសិទ្ធិកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល (NGO CRC)។ សមាជិក៥នាក់នៃក្រុមការពារកុមារបានចូលរួមក្នុងកិច្ចប្រជុំមួយចំនួនស្តីពី ការអភិវឌ្ឍន៍របស់កុមារ បណ្តាញកុមារ និងការទាក់ទាញមតិគាំទ្រ ដែលបានរៀបចំឡើងដោយអង្គការមូលនិធិសិទ្ធិកុមារ។ សមាជិក១នាក់ពីក្រុមការពារកុមារបានចូលរួមសិក្ខាសាលាស្តីពីយុត្តិធម៌កុមារ ដែលបានរៀបចំឡើងនៅទីក្រុងភ្នំពេញដោយមូលនិធិសង្គ្រោះកុមារអង្គការសហប្រជាជាតិ យូនីសេហ្វ (UNICEF) ជំនួយ ព្រះវិហារដាណឺម៉ាក (DCA) និងក្រសួងយុត្តិធម៌។

សកម្មភាពក្រុមការពារកុមារមានលក្ខណៈទូលំទូលាយ ប៉ុន្តែផ្តោតទៅលើការអប់រំសង្គមស៊ីវិលពីសិទ្ធិកុមារ និងការខិតខំប្រឹងប្រែងដើម្បីការពារសិទ្ធិទាំងនេះ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០០៧ ក្រុមការពារកុមារបានរៀបចំវគ្គផ្សព្វផ្សាយចំនួន១៧០វគ្គដើម្បីផ្តល់ពត៌មានពីសិទ្ធិកុមារ ពលកម្មកុមារ និងជួញដូរកុមារ។ សមាជិកសរុបចំនួន ១៥,៣៧៨ បានចូលរួមនៅក្នុងវគ្គដែលក្នុងនោះមានកុមារចំនួន ៦,០៨៣នាក់។ ការបង្កើនចំនួនក្រុមការពារកុមារនាំឱ្យមានភាពប្រសើរឡើងក្នុងវគ្គផ្សព្វផ្សាយ ដែលជាការកាត់បន្ថយនូវការផ្តល់ជំនួយពីអ្នកទាក់ទាញមតិគាំទ្រតាមបណ្តាខេត្ត និងការផ្តល់អំណាចដល់សមាជិកកុមារ។

បន្ថែមពីនេះទៅទៀត ក្រុមការពារកុមារបានជួយអ្នកទាក់ទាញមតិគាំទ្រតាមបណ្តាខេត្ត អ្នកសេវាសង្គមកិច្ច អ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ក្នុងការស្វែងរកការអនុញ្ញាតិពីអាជ្ញាធរពាក់ព័ន្ធ សំរាប់ធ្វើការស៊ើបអង្កេតការវាយតំលៃ និងការផ្តល់ជំនួយដល់ជនរងគ្រោះ កុមាររងគ្រោះ និងគ្រួសារក្រីក្រ។

**ករណីសិក្សាៈ ស៊ីនួន អាយុ ១៨ឆ្នាំ ជាសមាជិកក្រុមការពារកុមារ**

ខ្ញុំជាកូនទី៦ក្នុងចំណោមបងប្អូនប្រុសស្រី៧នាក់នៅក្នុងគ្រួសារ។ ក្រុមគ្រួសារខ្ញុំក្រីក្រណាស់ ហើយពួកគេរស់នៅក្នុងខេត្តកំពង់ចាម។ តាំងពីពួកគាត់បានលក់ផ្ទះ និងដីនៅខេត្តកំពង់ចាម ហើយបានផ្លាស់ប្តូរទីលំនៅដើម្បីស្វែងការងារមក ខ្ញុំមិនបានទទួលដំណឹងពីពួកគាត់ទេ ដែលពេលនោះខ្ញុំមានអាយុត្រឹមតែ១០ឆ្នាំប៉ុណ្ណោះ។ តាំងពីពេលនោះមក ខ្ញុំគ្មានផ្ទះសំបែង ឬក្រុមគ្រួសារនៅជាមួយទេ ប៉ុន្តែចុងក្រោយខ្ញុំបានសុំការសណ្តោសប្រណីពីព្រះសង្ឃ ហើយសព្វថ្ងៃខ្ញុំកំពុងស្នាក់នៅជាមួយព្រះសង្ឃ។

សព្វថ្ងៃខ្ញុំកំពុងរៀនថ្នាក់ទី១០។ ខ្ញុំជាធម្មតាចំណាយពេល១ ម៉ោងកន្លះដើម្បីជិះកង់ទៅសាលា។ ក្រោយពីចេញសាលាខ្ញុំស៊ីឈ្នួលដាំដំឡូងដែលខ្ញុំអាចទទួលបានប្រាក់ ៧,០០០រៀល (១.៧៥ ដុល្លារអាមេរិក) ក្នុង១ ថ្ងៃ ដោយសារខ្ញុំត្រូវការប្រាក់កាសសំរាប់ទិញសម្ភារៈសិក្សា រៀនគួរបន្ថែម និងចំណាយលើម្ហូបអាហារ។

នៅក្នុងឆ្នាំ ២០០៥ ខ្ញុំបានចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពីសិទ្ធិកុមារជាមួយអង្គការ លីកាដូ ហើយបន្ទាប់មក ខ្ញុំបាន

ក្លាយជាសមាជិកម្នាក់នៃក្រុមការពារកុមារ។ ឥឡូវនេះ ខ្ញុំបានយល់ដឹងច្រើនអំពីសិទ្ធិកុមារ ការជួញដូរកុមារ និងអាជីវកម្មកុមារ។ ហើយខ្ញុំបានទទួលការគាំទ្រពីមិត្តភក្តិជាច្រើន ហើយពួកគេបានជ្រើសរើសខ្ញុំធ្វើជាសមាជិកម្នាក់នៃក្រុមការពារកុមារ ហើយថ្មីៗនេះខ្ញុំត្រូវបានជ្រើសរើសជាអ្នកជំនួយការក្លឹបសិស្ស ហើយនិងកម្មវិធីផ្សេងទៀតនៅសាលា។ ខ្ញុំបានគេជ្រើសរើសជាអ្នកស្ម័គ្រចិត្ត សំរាប់ការពារការរីករាយដាលមេរោគអេដស៍ និងការប្រើប្រាស់គ្រឿងញៀន។

ខ្ញុំសប្បាយចិត្តណាស់ក្នុងការប្រើប្រាស់ចំនេះដឹងរបស់ខ្ញុំដើម្បីជួយដល់កុមារ ដែលមិនអាចអាន និងសរសេរតាមរយៈការបង្រៀនអក្ខរកម្ម និងការផ្សព្វផ្សាយស្តីពីសិទ្ធកុមារ និងការធ្វើអាជីកម្មកុមារ នៅក្នុងសហគមន៍ និងសាលារៀន។

ខ្ញុំសុបិន្ត និងប្រាថ្នាចង់រៀនអោយចប់វិទ្យាល័យ ហើយស្វែករកប្រភេទការងារដែលអាចជួយដល់ជនងាយរងគ្រោះ និងអ្នកក្រីក្រដែលបានបាត់ជីវិតដូចក្រុមគ្រួសារដូចជារូបខ្ញុំ។

### *សកម្មភាពទាក់ទាញមតិគាំទ្រ*

សកម្មភាពទាក់ទាញមតិគាំទ្រ របស់ការិយាល័យសិទ្ធិកុមារជាច្រើនត្រូវបានអនុវត្តន៏ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ រួមមាន ការសម្ភាសន៏ជាមួយអ្នកសាព័ត៌មាន ស្ពតទូរទស្សន៏ និងផ្សាយតាមវិទ្យុដែលអ្នកចូលរួមអាចទូរសព្ទ័ចូលរួម និងសួរសំណួរទៅកាន់សំរបសំរួលកម្មវិធី និងវាគ្មិន។ រាល់សកម្មភាពទាំងនេះបានបង្ហាញថាមានប្រជាប្រិយភាពយ៉ាងខ្លាំង។ ការិយាល័យសិទ្ធិកុមារធ្វើការសហការជាមួយ អង្គការមិនមែនរដ្ឋាភិបាលផ្សេងដើម្បីបង្ហាញសាធារណៈជន ពីបញ្ហាសិទ្ធិកុមារ រួមមានការជួញដូរកុមារ ពលកម្មកុមារ ការបំពារបំពានកុមារ និងការអប់រំ។ ក្នុងកម្មវិធីមួយដែលមានការអញ្ជើញពីវិទ្យុជាតិកម្ពុជា អ្នកសំរបសំរួលនៃការិយាល័យសិទ្ធិកុមារ និង អ្នកឃ្លាំមើលការរំលោភសិទ្ធិកុមារក៏រិតខ្ពស់បានផ្តល់នូវដំបូន្មានទៅដល ឪពុកម្តាយក្នុងការអប់រំកុមារ។

នៅថ្ងៃទី១ ខែមិថុនា ឆ្នាំ២០០៧ ការិយាល័យសិទ្ធិកុមារបានរៀបចំយុទ្ធនាការសិទ្ធិកុមារ នៅក្នុង៨កន្លែងដើម្បីអបអរសាទរទិវាកុមារអន្តរជាតិ។ នៅទីតាំងនីមួយៗ យុទ្ធនាការនេះបានជ្រើសរើសបញ្ហាសិទ្ធិកុមារជាក់លាក់ដើម្បីលើកកំពស់ការយល់ដឹងនៅក្នុងសហគមន៍។ ព្រឹត្តិការណ៍ត្រូវបានរៀបចំឡើងដោយអង្គការលីកាដូ ក្រោមកិច្ចសហប្រតិបត្តិការពីអាជ្ញាធរមូលដ្ឋាន ប៉ូលីស ព្រះសង្ឃ សិស្សានុសិស្ស និងលោកគ្រូអ្នកគ្រូ អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកសហគមន៍។ ព្រឹត្តការណ៍ និងសម្ភារៈអប់រំត្រូវបានផ្សព្វផ្សាយដោយប្រព័ន្ធសារពតិមាននៅក្នុងស្រុក ដូចជាទូរទស្សន៏ជាតិកម្ពុជា ទូរទស្សន៏ខ្មែរប៉ុស្តិ៍លេខ៩, ទូរទស្សន៏ស៊ីធីអិន និងកាសែតក្នុងស្រុក។

ការិយាល័យសិទ្ធិកុមារបានរៀបចំការជជែកពិភាក្សាចំនួន ៣៨ លើកតាមរយៈវិទ្យុអេហ្វអឹម៩៣.៥ និងវិទ្យុអេហ្វអឹម ១០៦។ ប្រធានបទទាំងអស់បានផ្តោតទៅលើបញ្ហាសិទ្ធកុមារ។ កម្មវិធីវិទ្យុត្រូវបានរៀបចំឡើងបានដោយមានការចូលរួម និងកិច្ចសហប្រតិបត្តិការជាមួយអង្គការជំនួយផ្នែកច្បាប់កម្ពុជា អង្គការទស្សនៈពិភពលោកកម្ពុជា អង្គការ CCASVA អង្គការហ្វ្រេន អង្គការ CCH អង្គការ ECPAT សាលា Lavalla មជ្ឈមណ្ឌលផ្ទះរបស់យើង អង្គការជួយស្ត្រីមានវិបត្ត អង្គការ SCADP អង្គកាលីកាដូ និងសមាជិកក្រុមការពារកុមារ។

បុគ្គលិកការិយាល័យសិទ្ធិកុមារចំនួន ៦នាក់បានធ្វើការជាមួយបុគ្គលិកអង្គការទស្សនៈពិភពលោកកម្ពុជាដើម្បីរៀបចំព្រឹត្តិការណ៍សាធារណៈពីរលើក។ លើកទី១ ផ្តោតលើពលករកុមារនៅតាមឡឥដ្ឋ ហើយត្រូវបានធ្វើឡើងនៅថ្ងៃទី១៨ ខែសីហា។ លើកទី២ នៅថ្ងៃទី២២ ខែវិច្ឆិការ នៅទីក្រុងភ្នំពេញ ហើយព្រឹត្តិការណ៍នោះផ្តោតលើពលករកុមារនៅក្នុងឧស្សាហកម្មក្លឹបកំសាន្ត។



បុគ្គលិកគំរោង និងសមាជិកក្រុមការពារកុមារបានចូលរួមដើរក្បួនចំនួនបីលើក ដែលពីរលើកផ្តោតលើការបណ្តុះបណ្តាលពីទំរង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ និងការរៀបចំគំរោងនៃអង្គការលីកាដូ ស្តីអំពីការជួញដូរ និងអាជីវកម្មផ្លូវភេទលើកុមារ ដែលត្រូវបានធ្វើឡើងក្នុងខេត្តសៀមរាប និងក្រុងព្រះសីហនុ ហើយលើកទី៣ ស្តីអំពីពលករកុមារនៅឡឥដ្ឋ ដែលត្រូវបានធ្វើនៅក្នុងស្រុកមុខកំពូល ខេត្តកណ្តាល។

ការដើរក្បួននៅក្រុងព្រះសីហនុ និងនៅខេត្តសៀមរាប គឺមានប្រធានបទ "រួមគ្នាប្រឆាំងការជួញដូរ និងអាជីវកម្មផ្លូវភេទកុមារ" ហើយមានគោលបំណងដើម្បីផ្សព្វផ្សាយអោយយល់ដឹងពីទំរង់នានានៃការរំលោភបំពាន និងផលប៉ះពាល់ដ៏ធ្ងន់ធ្ងរដែលកើតមានលើកុមារ។ នៅខេត្តសៀមរាប ក្បួនដង្ហែត្រូវបានធ្វើនៅថ្ងៃទី២ ខែតុលា ហើយមានអ្នកចូលរួមប្រមាណ ៤០០នាក់ ដែលក្នុងនោះមានលោកអភិបាលខេត្តរង ប៉ូលីស មន្ត្រីពាក់ពន្ធ័ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ព្រះសង្ឃ និងសមាជិកក្រុមការពារកុមារ។ នៅទីក្រុងព្រះសីហនុ ក្បួនដង្ហែរត្រូវបានរៀបចំធ្វើនៅថ្ងៃទី២៤ ខែសីហា ហើយមានអ្នកចូលរួមចំនួន៥០០នាក់ ដែលក្នុងនោះមាននាយកខុទ្ទកាល័យខេត្ត ប៉ូលីស មន្ត្រីពាក់ព័ន្ធ សមាជិកនៃក្រុមការពារកុមារ បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល និងព្រះសង្ឃ។ សកម្មភាពទាំងនេះបានលើកកំពស់ការយល់ដឹងរបស់សាធារណៈជនពីបញ្ហាជួញដូរកុមារ និងលើក

ទឹកចិត្ត មន្ត្រីរដ្ឋាភិបាល ប៉ូលីស និងសមាជិកសាធារណៈរួមមានទេសចរណ៍ជាដើម ធ្វើការរួមគ្នាដើម្បីការពារកុមារពីការរំលោភបំពាននេះ។




យុទ្ធនាការទាក់ទាញមតិគាំទ្រ "កុមារនៅក្នុងពន្ធនាគារៈ គ្មានឱកាសក្នុងការលូតលាស់" មានបំណងដើម្បីលើកកំពស់ការយល់ដឹងពីស្ថានភាពរស់នៅក្នុងពន្ធនាគាររបស់អនីតិជន និងកុមារដែលផ្ទុយទៅនឹងច្បាប់ដែលត្រូវបានធ្វើឡើងនៅថ្ងៃ៣១ ខែមករា ២០០៧ នៅបន្ទប់ប្រជុំនៃអង្គការលីកាដូ ដោយមានរបាយការណ៍ត្រូវបានចែកចាយៈ

- "ស្ថានភាពពន្ធនានៅកម្ពុជាៈ ថ្ងៃមួយក្នុងជីវភាពរស់នៅជា........" ដែលសរសេរដោយអង្គការលីកាដូ (របាយការណ៍នេះក៏បានផលិតជាសោតទស្សន៍ផងដែរ)
- "សុវត្ថិភាពសិទ្ធិកុមារនៅក្នុងប្រទេសកម្ពុជា" ដែលផ្តោតទៅលើការទទួលបានតំណាងផ្នែកច្បាប់ និងការឃុំខ្លួនមុនការវិនិច្ឆ័យនៃអនិតិជននៅក្នុងពន្ធនាគារជាច្រើននៅកម្ពុជា ដែលបោះពុម្ពផ្សាយដោយអង្គការជំនួយផ្នែកច្បាប់កម្ពុជា។

កំឡុងពេលសន្និសីទសារព័ត៌មាន ក្រុមមនុស្សដែលរួមមានអតីតអនិតិជន២នាក់ (នៅខាងក្រោយឆាក) ឳពុកម្តាយរបស់ទណ្ឌិត សមាជិក១នាក់ពីក្រុមការពារកុមារនៃអង្គការលីកាដូ មេធាវី១នាក់ពីអង្គការជំនួយផ្នែកច្បាប់កម្ពុជា និងអ្នកតំណាងម្នាក់មកពីលីកាដូ និង យូនីសេហ្វ បានប្រកាសប្រាប់សាធរណៈជន និងអ្នកសារព័ត៌មានក៏ដូចជាបានឆ្លើយនូវសំនួរដែលបានលើកឡើងទាក់ទងទៅនឹងបញ្ហា និងស្ថានភាពកុមារនៅក្នុងពន្ធនាគារកម្ពុជា។ សន្និសីទសារព័ត៌មានបានរៀបចំដោយវិទ្យុជាច្រើន (សំលេងសហរដ្ឋអាមេរិក វិទ្យុអាស៊ីសេរី និងវិទ្យុ BBC) និងកាសែតផ្សេងៗទៀត (The Cambodia Daily, Cambodge Soir និងកោះសន្តិភាពផងដែរ។

សកម្មភាពទី២សំរាប់យុទ្ធនាការគឺមានបង្រៀនអោយគូរគំនូរ និងតាំងពិពណ៌គំនូរសំរាប់ អនិតិជននៅក្នុងពន្ធនាគារ។ ការផ្តល់ឱកាសដល់អនិតិជនក្នុងពន្ធនាគារបញ្ចេញយោបល់ក្នុងការតស៊ូព្យាយាម ហើយជាមធ្យោបាយតែមួយគត់តាមរយៈការប្រើប្រាស់នូវការស្គាល់ទ្ធភាពពលកម្មនៃសិល្បៈព្យាបាល និងបង្កើតវេទិកាដែលអារម្មណ៍ និងគំនិតរបស់ពួកគេត្រូវបានបង្ហាញ។

វគ្គគូរគំនូរត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី៧-១៨ ខែមេសា នៅក្នុងពន្ធនាគារព្រៃស (CC2) ខេត្តកណ្តាល និង ខេត្តសៀមរាប។ អនិតិជនចំនួន ៦៦នាក់បានចូលរួមក្នុងសកម្មភាពនេះ។ និស្សិតមកពីសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈចំនួន៦នាក់ (ពីរនាក់សំរាប់ពន្ធនាគារនីមួយៗ) បានបង្រៀនកុមារនូវជំនាញប្លែកពីគ្នានៃគំនូរ។

ការតាំងពិពណ៌គំនូររូបភាពមានចំណងជើងថា "បទពិសោធន៍ និងក្តីស្រមៃគំនូររូបភាពដោយកុមារក្នុងពន្ធនាគារ" ត្រូវបានធ្វើនៅមជ្ឈមណ្ឌលវប្បធម៌ជាតិនៅក្នុងទីក្រុងភ្នំពេញចាប់ផ្តើមពី១៥-១៧ ខែកញ្ញា ឆ្នាំ២០០៧។ ការតាំងពិពណ៌ត្រូវបានដាក់បង្ហាញនូវការប្រមូលផ្តុំគំនូរដោយអនិតិជន ដែលបង្ហាញពីស្ថានភាពពន្ធនាគារ ការបញ្ចេញអារម្មណ៍ផ្ទាល់ខ្លួនលើប្រព័ន្ធយុត្តិធម៌ ហើយនឹងគំនិត និងក្តីស្រមៃរបស់ពួកគេក្នុងពេលអនាគត។

## ***ឧបករណ៍ និងសំភារៈសំរាប់ធ្វើការទាក់ទាញមតិគាំទ្រ***

- ផលិត និងបោះពុម្ពខិត្តបណ្ណ័ចំនួន៣៨០០ស្តីអំពីការជួញដូរកុមារ
- បោះពុម្ព ៦១ បរដា ហើយបានបង្ហាញទូទាំងប្រទេសកម្ពុជា (៥ខេត្ត) ដើម្បីលើកកំពស់ការយល់ដឹងរបស់សាធារណៈជននៅមុនពេល ឬកំឡុងពេលថ្ងៃសិទ្ធកុមារអន្តរជាតិ ១ មិថុនា ២០០៧។
- ផលិតវីដេអូអប់រំរយៈពេល ២០ នាទី ស្តីអំពីការជួញដូរ និង កុមារបំរើការងារតាមផ្ទះសំរាប់សកម្មភាព និងព្រឹត្តិការណ៍ផ្សព្វផ្សាយរបស់ក្រុមការពារកុមារ។
- បោះពុម្ពកូនសៀវភៅចំនួន ៣០០០ ក្បាលមានចំណងជើងថា "តើអ្នកអាចធ្វើអ្វីដើម្បីប្រឆាំង ការជួញដូរ និងធ្វើអាជីវកម្មផ្លូវភេទលើកុមារ?"
- ផលិត និងបោះពុម្ពកាតចំនួន៥០០០ (ខិតប័ណ្ណប្រភេទវែង) ស្តីអំពីសិទ្ធិសំខាន់ទាំង៤ របស់សិទ្ធិកុមារ ដែលគួរត្រូវបានគេរាយការណ៍សំរាប់ ការអន្តរាគមន៍នៅពេលមានករណីរំលោភសិទ្ធិកុមារ និងកន្លែងទំនេរសំរាប់កត់ត្រានូវលេខទូរសព្ទ័។ ខិត្តបណ្ណ័ទាំងនេះត្រូវចែកចាយអោយសមាជិកបណ្តាញ និងក្រុមការពារកុមារ និង ប្រជាពលរដ្ឋនៅក្នុងសហគមន៍។



- បោះពុម្ពផ្សាយនិមិត្តសញ្ញា ៤ប្រភេទ ស្តីអំពីកិច្ចការពារកុមារពីការធ្វើការជាមួយឧបករណ៍គ្រោះថ្នាក់ សំភារៈម៉ាស៊ីន និងកន្លែងឡឥដ្ឋ សំរាប់លក្ខ័ណការងារសុវត្ថិភាព។

## ***បទដ្ឋានអប្បបរមា***

ដើម្បីបញ្ចុះបញ្ចូលរដ្ឋាភិបាលអនុវត្តនូវច្បាប់ពលកម្មកុមារនៅក្នុងឡឥដ្ឋ និងការងារបំរើតាមផ្ទះ ដែលអាជ្ញាធរមូលដ្ឋាន និងអាជ្ញាធរជំនាញ ម្ចាស់ផ្ទះ និងក្រុមការពារកុមារបានរៀបចំកិច្ចប្រជុំ ដើម្បីបង្កើតយន្តការមួយដែលអាចជំរុញឱ្យមានការអនុវត្តច្បាប់នេះ។

កិច្ចប្រជុំពិភាក្សាចំនួនបីបានប្រព្រឹត្តិនៅស្រុកមុកកំពូលខេត្តកណ្តាល (រោងចក្រឡឥដ្ឋ) និងខណ្ឌដង្កោ ក្រុងភ្នំពេញ (ពលកម្មកុមារតាមផ្ទះ) ពេញមួយឆ្នាំដើម្បីពិភាក្សាសេចក្តីព្រៀងពី ទដ្ឋានការងារអប្បបរមា។ ឯកសារព្រៀងត្រូវបានចុះហត្ថលេខាជាផ្លូវការនៅថ្ងៃ១៧ ខែកញ្ញា (រោងចក្រឡឥដ្ឋ) និងថ្ងៃទី៤ ខែតុលា

(ការងារតាមផ្ទះ)។ ចាប់ពីខែតុលា ដល់ខែធ្នូ ២០០៧ ឯកសារត្រូវបានចែកចាយដល់គ្រប់រោងចក្រឡូតដ្ឋ ឪពុកម្តាយរបស់កុមារធ្វើការនៅឡូតដ្ឋ នៅតាមផ្ទះ និងកុមារកំពុងធ្វើការនៅក្នុងសហគមន៍ ដូច្នេះ ពួកគេអាចយល់ និងបានអនុវត្តបទដ្ឋានការងារដែលបានលើកឡើងប្រកបដោយប្រសិទ្ធិភាព។

សេចក្តីព្រៀងបទដ្ឋានអប្បបរមាគឺជាឧបករណ៍ទាក់ទាញមតិគាំមួយដ៏សំខាន់ ដែលអាចប្រើប្រាស់ដោយសហគមន៍ និងសង្គមស៊ីវិលដើម្បីបញ្ចុះបញ្ចូលនិយោជក អាជ្ញាមូលដ្ឋាន និង រដ្ឋាភិបាលឱ្យអនុវត្តបទដ្ឋានអប្បបរមាក្នុងពលកម្មកុមារ។ អង្គការ ពលកម្មអន្តរជាតិ ក៏មានការបង្ហាញពីការចាប់អារម្មណ៍លើបទដ្ឋាននេះដែរដោយបានសំណូមពរថតចំលងនៃឯកសារនោះ ហើយសង្ឃឹមថាអង្គការពលកម្មអន្តរជាតិនឹងប្រើប្រាស់ឯកសារនោះជាគំរូ និងចែកចាយបទដ្ឋានអប្បបរមារទៅគ្រប់រោងចក្រឡូតដ្ឋនៃតំបន់គោលដៅនៅក្នុងខេត្តសៀមរាប។

ក្រោយបានឃើញសេចក្តីព្រៀងបទដ្ឋានអប្បបរមារនៃលក្ខ័ណការងារ ម្ចាស់រោងចក្រឡូតដ្ឋ តាមរយៈសមាគមន៍ម្ចាស់រោងចក្រឡូតដ្ឋនៅក្នុងស្រុកមុខកំពូលបានធ្វើសេចក្តីព្រៀកិច្ចសន្យាការងារហើយបញ្ជូនមកអង្គការលីកាដូ និងអង្គការជំនួយផ្នែកច្បាប់កម្ពុជាដើម្បីផ្តល់យោបល់ និងជំនួយបច្ចេកទេស។

ស្របទៅនឹងការបញ្ចប់លើសេចក្តីព្រៀងបទដ្ឋានអប្បបរមារនៃកុមារបំរើការងារតាមផ្ទះ សេចក្តីព្រៀងនេះត្រូវបានបង្ហាញទៅក្រុមការងារផ្នែកកុមារបំរើការងារតាមផ្ទះ ដែលរួមមានអ្នកតំណាងចំនួន ៣០នាក់មកពីអង្គការពលកម្មអន្តរជាតិ គណៈកម្មការសិទ្ធិកុមារ មន្ទីការងារក្រុងភ្នំពេញ មន្ទីសង្គមកិច្ចក្រុងភ្នំពេញ និងមន្ទីទេសចរណ៍ក្រុងភ្នំពេញ និងបណ្តាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកជាច្រើនទៀត។ បន្ទាប់មកទៀតក្រុមការងារបានផ្តល់អនុសាសន៍ដើម្បីកែតំរូវច្បាប់ការងារទៅកាន់ក្រសួងការងារ។ អង្គការពលកម្មអន្តរជាតិបានចាប់អារម្មណ៍យ៉ាងខ្លាំងហើយបាននិយាយថា យើងគួតែផ្តល់ថវិការទៅក្រសួងការងារដើម្បីធ្វើវិសោធនកម្មច្បាប់ការងារជាថ្មី។

## ***ការស៊ើបអង្កេត និងការឃ្លាំមើល***

ក្នុងឆ្នាំ ២០០៧ អ្នកឃ្លាំមើលការរំលោភសិទ្ធិកុមារបានទទួល និងធ្វើការស៊ើបអង្កេត ២៨៤ករណី ដែលក្នុងនោះមានជនរងគ្រោះ ៣០៤ នាក់ (ស្ត្រី ២៧១នាក់)។

## ករណីរំលោភសិទ្ធិកុមារដែលទទួលដោយការិយាល័យកុមារក្នុងឆ្នាំ២០០៧




| | |
|---|---|
| RA = រំលោភសេពសន្ថវៈ/ប៉ុនប៉ងរំលោភ | IAD = ការចាប់ខ្លួន/ឃុំខ្លួនខុសច្បាប់ |
| K = មនុស្សឃាដ | DT = គំរាមសំលាប់ |
| AK = ការប៉ុនប៉ងធ្វើមនុស្សឃាដ | ED = បង្ខំបាត់ខ្លួន |
| T = ទារុណកម្ម | IA = បៀតបៀនកេរខ្មាស |
| PA = បង្ករបួសស្នាម | CDV = អំពើហិង្សាប្រឆាំងកុមារបំរើការងារតាមផ្ទះ |
| HTS = ការជួញដូរមនុស្ស-ការជួញដូរផ្លូវភេទ | A = ការចាប់ជំរិត |
| HTL = ការជួញដូរមនុស្សដើម្បីពលកម្ម | SC = ករណីពិសេស |
| HTA = ការជួញដូរមនុស្សដើម្បីចិញ្ចឹម | |

### ជំនួយដល់ជនរងគ្រោះ

ការិយាល័យសិទ្ធិកុមារក៏បានផ្តល់ជំនួយសំភារៈសំរាប់កុមាររងគ្រោះដោយការរំលោភសិទ្ធិកុមារ និងកុមារងាយរងគ្រោះផងដែរ។ ជាសរុបមកមានកុមារចំនួន ៤០៥ នាក់បានទទួលជំនួយទាំងនោះ ដូចជាការផ្តល់កង់សំរាប់កុមារដែលនៅឆ្ងាយពីសាលារៀន បញ្ជូនជនរងគ្រោះដោយការរំលោភសេពសន្ថវៈទៅកាន់មន្ទីរពេទ្យដើម្បីព្យាបាល និងការផ្តល់សំភារៈសិក្សា។ នៅក្នុងទិវាសិទ្ធិកុមារអន្តរជាតិ បុគ្គលិកសិទ្ធិកុមារទាំងអស់រួមទាំងមានជំនួយពីបុគ្គលិកលីកាដូ និងអង្គដៃគូជាច្រើន បានរៀបចំចែកចាយនូវសំភារៈសំខាន់ៗដូចជា សំភារៈសិក្សា តុក្កតា សំភារៈសំរាប់ដេក សំភារៈប្រើប្រាស់ប្រចាំថ្ងៃ ទៅដល់កុមារ និងស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារចំនួន ១៤ ពន្ធនាគារដែលពន្ធនាគារមួយនៅភ្នំពេញ និងផ្សេងទៀតនៅតាមបណ្តាខេត្ត។ សរុបមកមានជនរងគ្រោះទាំងអស់មានចំនួន ៩៦៩ នាក់បានទទួលជំនួយ។

## *ជំនួយផ្នែកច្បាប់ និងសេវាបញ្ជូន*

បុគ្គលិកសិទ្ធិកុមារធ្វើកិច្ចអន្តរាគមន៍/សកម្មភាព និងបំរើជាច្រើនក្នុងកំឡុងពេលដំណើរការមានដូចខាងក្រោម:

- ៧៤ករណីបានធ្វើអន្តរាគមន៍ ទៅកាន់នគរបាល កងរាជអាវុធហត្ថ និងអាជ្ញាធរមូលដ្ឋាន
- ៨ករណីបានអន្តរាគមន៍ទៅមន្ទីការងារ និងសង្គមកិច្ច
- ២០២ករណីត្រូវបានអន្តរាគមន៍/បញ្ជូនទៅតុលាការ ។
- ៥៧ករណីរបានបញ្ជូនទៅអង្គការមិនមែនរដ្ឋាភិបាលសំរាប់សេវាកម្មផ្នែកច្បាប់ ឬតំណាងផ្នែកច្បាប់

**ករណីដែលបានបញ្ជូនសំរាប់សេវាកម្មច្បាប់**

| **ភ្នាក់ងារ/អង្គភាព** | **ចំនួនករណីរ** |
|---|---|
| ជំនួយផ្នែកច្បាប់កម្ពុជា (LAC) | ១៦ |
| គំរោងការពារយុត្តិធមិកុមារ (PJJ) | ២១ |
| លីកាដូ | ៩ |
| អង្គការសេវាផ្នែកច្បាប់សំរាប់កុមារ និងស្ត្រី (LSCW) | ៦ |
| ក្រុមអ្នកច្បាប់ការពារសិទ្ធិមនុស្សកម្ពុជា (CDP) | ២ |
| គណ:មេធាវីកម្ពុជា (BAC) | ១ |
| មជ្ឈមណ្ឌលព័ត៌មានស្ត្រីកម្ពុជា (CWCC) | ១ |
| សកម្មភាពដើម្បីកុមារ (APLE) | ១ |
| **សរុប** | **៥៧** |

## **លទ្ធផលសំរេចបាន**

- ប្រជាពលរដ្ឋក្នុងសហគមន៍មានការចាប់អារម្មណ៍លើបញ្ហាសិទ្ធិកុមារ ស្គាល់ក្រុមការពារកុមារកាន់តែប្រសើរឡើង មានកិច្ចសហប្រតិបត្តការយ៉ាងល្អក្នុងការរាយការណ៍ពីករណីការបំពាបំពានសិទ្ធិកុមារហើយ និងការគាំទ្រសកម្មភាពក្រុម ។
- ក្រុមការពារកុមារ និងសមាជិកបណ្តាញក្រុមការពារកុមារបានយល់ដឹងពីតំរូវការសំរាប់ការងារជាក្រុមតាមរយ:រកឱ្យឃើញសំគាល់តំរូវការ និងរៀបចំផែនការសកម្មភាព (ពួកគេបានបង្កើតផែនការសកម្មភាពសំរាប់ឆ្នាំ២០០៨) បន្ទាប់មកពួកគាត់បានបញ្ជូនមកអ្នកទាក់ទាញមតិគាំទ្រសិទ្ធិកុមារនៃអង្គការលីការដូ

ការគ្រោងដើម្បីរាយការណ៍ករណី ស្វែងរកជំនួយសង្គមសំរាប់កុមាររងាយរងគ្រោះ ហើយលើកទឹកចិត្តសហគមន៍ឱ្យចូលរួមក្នុងសកម្មភាពនោះ ។

- សមាជិកក្រុមការពារកុមារមួយចំនួនអាចធ្វើការអន្តរាគមន៍ករណីរំលោភសិទ្ធិកុមារទៅអាជ្ញាធរពាក់ពន្ធ័ ។
- ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍បានបង្ហាញនូវការកែប្រែការប្រព្រឹត្តរបស់ខ្លួនដូចជាការបញ្ជូនកូនៗរបស់គាត់ទៅសាលារៀនវិញ បញ្ឈប់ការប្រើកុមារឱ្យធ្វើការងារដើម្បីរកប្រាក់ចំនូលគ្រួសារ បន្តឱ្យកុមារធ្វើការងារប៉ុន្តែបញ្ជូនពួកគេទៅសាលារៀនក្នុងរយៈពេលកន្លះថ្ងៃ ។
- អាជ្ញាធរមូលដ្ឋានបានចាប់ផ្តើមឆ្លើយតប និងអន្តរាគមន៍ងករណីបំពាបំពានកុមារដោយខ្លួនរបស់ពួកគេតាមរយៈទាក់ទងគ្រួសារ អង្គការ ហើយធ្វើការស៊ើបអង្កេត ។ អាជ្ញាធរមូលដ្ឋានបានធ្វើដំណើរមកលីកាដូជាទៀងទាត់ដើម្បីរាយការណ៍ពីករណី សំណើរសុំជំនួយសំរាប់ជនរងគ្រោះ និងនាំជនរងគ្រោះមកលីកាដូ ។ លើសពីនេះទៅទៀត ពួកគេបានចាប់ផ្តើមរាយការណ៍រាល់ករណីទៅក្រុមការពារកុមារ និងសមាជិកសហគមន៍ និងបន្តសកម្មភាបផ្សព្វផ្សាយ ។
- បង្កើនកិច្ចសហប្រតិបត្តិការរវាងអ្នកសេវាសង្គមមកពីអង្គការ និងមជ្ឈមណ្ឌលជំនាញ ជាមួយនឹងបុគ្គលិកសិទ្ធិកុមារនៃអង្គការលីកាដូ ។
- កិច្ចអន្តរាគមន៍តំណាងជនរងគ្រោះកាន់តែកើនឡើង ដោយសារតែមានការកើនឡើងនូវការរាយការណ៍ពីបណ្តាញក្រុមការពារកុមារ ។
- សហគមន៍បានផ្តល់ទីកន្លែងក្នុងគោលបំណងដើម្បីបន្តសកម្មភាពផ្សព្វផ្សាយ និងរៀបចំកិច្ចប្រជុំបណ្តាញសំរាប់សមាជិកក្រុមការពារកុមារជាច្រើនទៀត ។

□□□

# ការិយាល័យប្រឆាំងនឹងអំពើទារុណកម្ម

ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មផ្តល់សេវាយ៉ាងទូលំទូលាយដល់ជនរងគ្រោះ ដើម្បីជួយពួកគេក្នុងការស្តារលទ្ធភាពពលកម្មនៃសរីរាង្គកាយខាងផ្លូវចិត្តឱ្យមានភាពល្អប្រសើឡើង ។ សេវាកម្មទាំងនោះរួមមាន ការស្តារឡើងវិញ ផ្នែកផ្លូវកាយ ផ្នែកផ្លូវចិត្ត និងផ្នែកសេដ្ឋកិច្ចនៃរាល់គ្រប់ទំរង់អំពើទារុណកម្មដែលប្រព្រឹត្តដោយប៉ូលិស មន្ត្រីពន្ធគារ ឬដោយមន្ត្រីរដ្ឋាភិបាលផ្សេងៗទៀត ព្រមទាំករណីអំពើហិង្សាក្នុងគ្រួសារ និងរាល់ទំរង់ហិង្សា ធ្ងន់ធ្ងរផ្សេងទៀតដែលប្រព្រឹត្តិដោយជនស៊ីវិលផងដែរ ។



## គោលបំណង

- ដើម្បីផ្តល់សេវាកម្មស្តាលទ្ធភាពពលកម្មប្រកបដោយគុណភាពនិង ការពារជនរងគ្រោះដោយអំពើទារុណកម្មនិង អំពើហិង្សាធ្ងន់ធ្ងរផ្សេងទៀត ហើយនឹងដើម្បីចាត់វិធានការរារាំងការប្រើប្រាស់អំពើទារុណកម្មនៅក្នុងប្រទេសកម្ពុជា ។
- ដើម្បីអនុវត្តនូវការហូរចូលនៃចំនួនអតិថិជន និងពន្លឿនប្រព័ន្ធវាយតំលៃបង្ហាញអំពីសមត្ថភាពគំរោង ដើម្បីវាស់ស្ទង់ផលប៉ះពាល់នៃសេវាកម្មស្តាលទ្ធភាពពលកម្មរបស់ខ្លួន ។
- ដើម្បីបណ្តុះបណ្តាលបុគ្គលិកលីកាដូឱ្យស្គាល់ពីសុខភាពផ្លូវចិត្ត ផ្តល់ប្រឹក្សាយោបល់ និងសេវាសង្គម កិច្ច ។
- ដើម្បីរៀបចំ អនុវត្ត និងពង្រឹងការថែរក្សាសំរាប់អ្នកផ្តល់ការថែរក្សា/ កម្មវិធីគ្រប់គ្រងភាពតានតឹងសំរាប់បុគ្គលិកនៅទីក្រុងភ្នំពេញ និងតាមខេត្ត ព្រមទាំងមនុស្សដែលសក្តិសមផ្សេងទៀតដែលអាចធ្វើការទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងអតិថិជន ។
- កំណត់ដៃគូសក្តានុពល (អង្គការមិនមែនរដ្ឋាភិបាល បុគ្គលសំខាន់ៗ បណ្តាញសហគមន៍ ។ល។) ដែលអាចសហការជាមួយគំរោងក្នុងគោលបំណងដើម្បីបង្កើនទំហំ និងប្រសិទ្ធិភាពនៃសេវាកម្មទៅដល់ក្រុមគោលដៅនៃគំរោង ។
- ដើម្បីទប់ស្កាត់វប្បធម៌នៃអំពើទារុណកម្ម និងការប្រព្រឹត្តិដ៏សាហាវដែលកើតមានឡើងនៅក្នុងការអនុវត្តច្បាប់ និងស្ថាប័នផ្សេងៗ តាមរយៈការបង្កើនការយល់ដឹង និងវិធានការទៅលើបញ្ហា និងលើកកំពស់ការអនុវត្តអោយកាន់តែល្អប្រសើរ ។

## ផលសំរេចបាន

កាិយាល័យប្រឆាំងនឹងអំពើទារុណកម្មប្រតិបត្តការការងារនៅក្នុងកាិយាល័យលីកាដូប្រចាំទីក្រុងភ្នំពេញ ដោយសហការជាមួយនឹងអ្នកឃ្លាំមើលការរំលោភសិទ្ធិមនុស្សនៅកាិយាល័យតាមបណ្តាខេត្ត ។ គំរោងនេះផ្តល់សេវាស្តាលទ្ធភាពពលកម្មទៅដល់ជនរងគ្រោះដោយសារការរំលោភបំពានសិទ្ធិមនុស្សធ្ងន់ធ្ងរ ដែលត្រូវការជំនួយសង្គ្រោះផ្នែកផ្លូវកាយ និងផ្លូវចិត្ត ។ ការរំលោភបំពានទាំងនោះរួមមាន ការរំលោភសេពសន្ថវៈ អំពើហិង្សាក្នុងគ្រួសារធ្ងន់ធ្ងរ អំពើទារុណកម្មដែលអនុម័តដោយរដ្ឋ ការវាយប្រហារដោយទឹកអាស៊ីដ និងករណីផ្សេងៗទៀត ដែលកាិយាល័យប្រឆាំងនឹងអំពើទារុណកម្មបានធ្វើដោយមានកិច្ចសហប្រតិបត្តិការជាមួយកាិយាល័យលីកាដូផ្សេងទៀត ។

នៅក្នុងឆ្នាំ២០០៧ នេះ កាិយាល័យប្រឆាំងនឹងអំពើទារុណកម្មបានធ្វើការទៅលើករណីចំនួន ១៨៦ ដែលក្នុងនោះ មាន៧៦ករណីកើតឡើងនៅឆ្នាំ២០០៦ ។ ក្នុងចំណោមករណីសរុប មាន១៤៨ករណី ជនរងគ្រោះបានដាក់ពាក្យបណ្តឹងមកដោយផ្ទាល់ ។ នៅសល់៣២ករណីទៀតគឺជាសាច់ញាតិរបស់ជនរងគ្រោះដែលត្រូវការជំនួយផងដែរ

កាិយាល័យប្រឆាំងអំពើទារុណកម្មផ្តល់សេវាស្តាលទ្ធភាពពលកម្មចំនួន៤ គឺការផ្តល់ការប្រឹក្សាយោបល់ សេវាសង្គមកិច្ច សេវាព្យាបាល និងសេវាផ្នែកច្បាប់ ។ តារាងខាងក្រោមបង្ហាញពីចំនួនករណីដែលទាក់ទងនឹងសេវាទាំងនេះពេញមួយឆ្នាំ២០០៧ ។ ករណីខ្លះពាក់ព័ន្ធនឹងសេវាច្រើនជាងមួយ ។

**សេវាស្តារលទ្ធភាពពលកម្មដែលផ្តល់ដោយកាិយាល័យប្រឆាំងនឹងអំពើទារុណកម្ម ឆ្នាំ២០០៧**



តារាងខាងក្រោមបង្ហាញពីភាពញឹកញាប់នៃសេវាស្តារលទ្ធភាពពលកម្ម ដែលផ្តល់ដោយការិយាល័យប្រឆាំងនឹងអំពើទារុណកម្ម និងចំនួនសេវាបញ្ជូន។ នៅក្នុងករណីជាបន្ទាន់ ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មនឹងបញ្ជូនអតិថិជនទៅអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត ឬស្ថាប័នរាជរដ្ឋាភិបាលដែលអាចផ្តល់សេវាពេទ្យ និងការព្យាបាលដោយពេទ្យជំនាញ។

**ចំនួននៃសេវាស្តាលទ្ធភាពពលកម្មដែលកម្មវិធីប្រឆាំងនឹងអំពើទារុណកម្មផ្តល់ជូនអតិថិជន ឆ្នាំ២០០៧**




បន្ថែមលើផលសំរេចបានជាក់ស្តែងដែលបានពិភាក្សាខាងលើ បុគ្គលិករបស់ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មដែលមានបទពិសោធន៍បានបង្កើនទំនាក់ទំនងដែលមានការទុកចិត្តរវាងពួកគេផ្ទាល់ និងជាមួយអតិថិជន។

## ផលប៉ះពាល់

- អតិថិជន និងជនរងគ្រោះអាចដោះស្រាយបញ្ហារបស់ពួកគេកាន់តែប្រសើរឡើង
- ក្រុមគ្រួសាររបស់អតិថិជនបានបង្កើនការយល់ដឹងពីរបៀបក្នុងការគាំទ្រជនរងគ្រោះនៅក្នុងគ្រួសាររបស់ពួកគេ
- អតិថិជនមានស្ថានភាពសុខភាពល្អប្រសើរបន្ទាប់ពីទទួលបានការព្យាបាលជំងឺ
- សេចក្តីទុកចិត្ត និងទំនាក់ទំនងរវាងក្រុមគ្រួសាររបស់អតិថិជន និងបុគ្គលិកត្រូវបានបង្កើនឡើង

- បុគ្គលិករបស់ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មបានទទួលចំណេះដឹង សមត្ថភាព និងបទពិសោធន៍បន្ថែមទៀតពីការងាររបស់ពួកគេ។
- យន្តការនៃការងារស្តាលទ្ធភាពពលកម្មរបស់ការិយាល័យប្រឆាំងនឹងអំពើទារុណកម្មមានលក្ខណៈល្អប្រសើច្បាស់លាស់ និងពិតប្រាកដ។
- សេវាស្តារលទ្ធភាពពលកម្មរបស់កម្មវិធីនេះបានកើនឡើង និងកាន់តែមានប្រសិទ្ធិភាព។
- បុគ្គលិកលីកាដូ (បុគ្គលិកតាមបណ្តាខេត្ត) កាន់តែយល់អំពីទស្សនាទានអំពើទារុណកម្ម និងការគ្រប់គ្រងភាពតានតឹងបន្ទាប់ពីពួកគេបានទទួលការបណ្តុះបណ្តាលពីអ្នកសំរបសំរួល និងអ្នកផ្តល់យោបល់របស់ការិយាល័យប្រឆាំងនឹងអំពើទារុណកម្ម។
- បុគ្គលិកលីកាដូបានយល់កាន់តែច្បាស់ពីគំរោងស្តាលទ្ធភាពពលកម្មនៃការិយាល័យប្រឆាំងអំពើទារុណកម្មដូចនេះហើយទំនាក់ទំនងរវាងការិយាល័យប្រឆាំងអំពើទារុណកម្ម និងការិយាល័យតាមបណ្តាខេត្តកាន់តែប្រសើឡើង។
- បង្កើនកិច្ចពិភាក្សាជាសាធារណៈស្តីពីច្បាប់ប្រឆាំងអំពើទារុណកម្ម និងអំពើហិង្សាដទៃទៀត សំរាប់ប៉ូលីសអតិថិជន ក៏ដូចជាសហគមន៍ទាំងមូលនៅពេលដែលអនុវត្តន៍ការងារនៅតាមមូលដ្ឋាន។
- បានធ្វើឱ្យប្រសើឡើងនូវការគ្រប់គ្រងករណី និងនិតិវិធីច្បាស់លាស់
- បង្កើនការយល់ដឹងពីជនរងគ្រោះដោយអំពើទារុណកម្ម និងការរំលោភបំពានសិទ្ធិមនុស្សផ្សេងៗទៀតដល់អង្គការដៃគូ
- ប្រព័ន្ធការងារក្នុងការិយាល័យកាន់តែប្រសើរឡើង

□□□

# ការិយាល័យពេទ្យ

*ក្រុមគ្រូពេទ្យអង្គការលីកាដូ ផ្តល់សេវាពិនិត្យសុខភាពដល់អ្នកទោស ក្នុងពន្ធនាគារនៅភ្នំពេញ និងបណ្តាខេត្ត-ក្រុងចំនួន ១២ ជារៀងរាល់ខែ ព្រមទាំងបានផ្តល់សេវាព្យាបាលដល់អ្នកទោស និងមន្ត្រីពន្ធនាគារផងដែរ ។ ក្រុមគ្រូពេទ្យក៏បានផ្តល់ម្ហូបអាហារូបត្ថម្ភ និងការព្យាបាលពិសេស១ផ្សេងទៀត ដើម្បីបំពេញតំរូវការចាំ បាច់នានាដល់ស្ត្រីមានផ្ទៃពោះនៅក្នុងពន្ធនាគារ និងកូន១ របស់អ្នកទោសស្ត្រី រួមទាំងក្រុមជនដែលងាយរងគ្រោះ ផ្សេងទៀត ។ នៅ ការិយាល័យភ្នំពេញ ក្រុមគ្រូពេទ្យក៏បានពិនិត្យព្យាបាលដល់ជនរងគ្រោះដោយ ករណីរំលោភសិទ្ធិមនុស្សផងដែរ ។*



## <u>គោលបំណង</u>

- ដើម្បីផ្តល់ និងសំរបសំរួលការថែទាំផ្នែកវេជ្ជសាស្ត្រសមរម្យឱ្យទណ្ឌិត និងមន្ត្រីពន្ធនាគារ រួមទាំងការផ្សព្វផ្សាយនៃការផ្តល់ឱ្យដ៏សមស្របរបស់រដ្ឋ/ការគ្រប់គ្រងពន្ធនាគារ និងការផ្តល់ការគាំទ្ររបស់ក្រុមគ្រួសារ/សហគមន៍ ។

- ដើម្បីផ្តល់ការព្យាបាលដល់ជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ប្រយោជន៏ដើម្បីទទួលយក និងផ្តល់នូវភស្តុតាំងសំរាប់ការទារសំណងរបស់បុគ្គលមួយ១ និងតបតការរំលោភបំពានបែបនេះ ។

- ដើម្បីរៀបចំឱ្យមានការព្យាបាលទណ្ឌិតនៅកម្ពុជាដោយយោងទៅតាមទីតាំង និងទំហំនៃពន្ធនាគារ ហើយនឹងស្ថានភាពពន្ធនាគារនីមួយ១ ។ ដើម្បីធានាថា អ្នកទោសដែលមានជំងឺត្រូវបានទទួលការព្យាបាល ។

- ដើម្បីរកឱ្យឃើញនូវមូលហេតុនៃការស្លាប់នៅក្នុងពន្ធនាគារ និងការធ្វើទារុណកម្ម ឬការព្យាបាលដោយមន្ត្រីពន្ធនាគារ ឬបុគ្គលិកពន្ធនាគារ ។

- ដើម្បីព្យាបាលអ្នកជំងឺ រៀបចំឱ្យមានការបញ្ជូនទៅមន្ទីរពេទ្យ ផ្តល់សំភារៈមូលដ្ឋាន និងប្រមូលផ្តុំទិន្នន័យពីការរងរបួស និងជំងឺផ្សេង១ ។

- ដើម្បីផ្តល់ព័ត៌មានសំខាន់នៃសេវាកម្មសុខភាពពន្ធនាគារធៀបទៅនឹងបទដ្ឋានអន្តរជាតិ ។

- ដើម្បីផ្តល់នូវអាហារបន្ថែម ឱសថ និងសេវាកម្មផ្សេងៗទៀតទៅក្រុមជនងាយរងគ្រោះនៅក្នុងពន្ធនាគារ និងខាងក្រៅពន្ធនាគារ ។

- ដើម្បីរកឱ្យឃើញ និងលើកឡើងនូវមូលហេតុនៃបញ្ហាសុខភាពជាចំបងនៅក្នុងពន្ធនាគារ ។ ដើម្បីផ្តួចផ្តើមគំនិតក្នុងការអប់រំពីការការពារសុខភាព និងកម្មវិធីអនាម័យនៅក្នុងពន្ធនាគារ ។

- ដើម្បីផ្តល់សេវាកម្មវេជ្ជសាស្ត្រជូនជនងាយរងគ្រោះបំផុតដែលកំពុងរស់នៅក្នុងតំបន់បណ្តេញចេញ និងការតាំងទីលំនៅថ្មីនៅក្នុងទីក្រុងភ្នំពេញ និងតាមបណ្តាខេត្តបន្ទាន់មួយចំនួនទៀត ។

**<u>ផលសំរេចបាន</u>**

ការិយាល័យពេទ្យមានសកម្មភាពសំខាន់ៗបីគឺ:

- ឃ្លាំមើលសុខភាពអ្នកទោស និងមន្ត្រីពន្ធនាគារ
- ផ្តល់សេវាកម្មវេជ្ជសាស្ត្រនៅតំបន់តាំងទីលំនៅថ្មីភូមិអណ្តូង និងតំបន់តាមបណ្តាខេត្តដែលត្រូវបានគេបណ្តេញចេញ ឬ តំបន់តាំងទីលំនៅថ្មី ។
- ផ្តល់ការព្យាបាលជូនជនរងគ្រោះដោយការរំលោភសិទ្ធិនុស្ស ។

***សេវាកម្មសុខភាពនៅពន្ធនាគារ***

ការិយាល័យពេទ្យបានផ្តល់ការថែទាំយ៉ាងទៀតទាត់ជូនអ្នកទោសក្នុងពន្ធនាគារ១២កន្លែង ។ ការថែរក្សានេះផ្តោតទៅលើ:

- ការលើកកំពស់សុខភាពដោយឃ្លាំមើលលើការរំលោភបំពានសិទ្ធិមនុស្ស និងការធ្វើទារុណកម្ម ។
- ធ្វើអន្តរាគមន៍ជាបន្ទាន់ពេលមានបញ្ហាសុខភាព ។
- បញ្ជូនអ្នកជំងឺទៅមន្ទីរពេទ្យពេលមានករណីធ្ងន់ធ្ងរ
- ឃ្លាំមើលស្ថានភាពរស់នៅក្នុងបន្ទប់ឃុំឃាំង
- ធ្វើការស៊ើបអង្កេតពីការស្លាប់នៅក្នុងពន្ធនាគារ ។

ការិយាល័យពេទ្យក៏បានផ្តល់អាហារបន្ថែមសំរាប់ស្ត្រីមានផ្ទៃពោះ ទារក កុមារ ចាស់ជរា និង អ្នកដែលមានជំងឺធ្ងន់ធ្ងរ ។

នៅក្នុងឆ្នាំ ២០០៧ ការិយាល័យពេទ្យបានផ្តល់ជំនួយវេជ្ជសាស្ត្រជូនអ្នកជំងឺចំនួន ៨.៤១៨ លើកនៅពេលវេលាខុសៗគ្នា។

**មនុស្សដែលបានទទួលការព្យាបាលពីការិយាល័យពេទ្យសំរាប់កម្មវិធីពន្ធនាគារក្នុងឆ្នាំ២០០៧**

| | ពន្ធនាគារ | ចំនួនអ្នកទោស | | ចំនួនឆ្មាំពន្ធនាគារ | | សរុប | ចំនួនដង |
|---|---|---|---|---|---|---|---|
| | | ពុរស | ស្ត្រី | បុរស | ស្ត្រី | | |
| ១ | ទួលស្លែង | ១១០ | ០ | ៥០ | ០ | ១៦០ | ១១ |
| ២ | ប៉ៃហ្ស៊ី | ៣៥៨ | ៣០ | ១៤ | ០ | ៤០២ | ១១ |
| ៣ | តាខ្មៅ | ៤៥០ | ១០៣ | ៥ | ០ | ៥៥៨ | ១១ |
| ៤ | ព្រៃវែង | ៥៥៥ | ៤៧ | ៧៦ | ១៣ | ៦៩១ | ៩ |
| ៥ | ស្វាយរៀង | ៤០៣ | ៥៩ | ៩០ | ១៨ | ៥៧០ | ៩ |
| ៦ | តាកែវ | ៧៤១ | ១០៦ | ១០៥ | ៩ | ៩៦១ | ១២ |
| ៧ | ក្រុងព្រះសីហនុ | ៦១៥ | ៧៤ | ៣៩ | ៣ | ៧៣១ | ១១ |
| ៨ | កោះកុង | ៤០៣ | ៧៩ | ២៨ | ១ | ៥១១ | ១១ |
| ៩ | ពោធិ៍សាត់ | ២៣៨ | ២៨ | ២២ | ១ | ២៨៩ | ១០ |
| ១០ | បាត់ដំបង | ១២៨៤ | ២៧១ | ៣៣ | ០ | ១៥៨៨ | ១០ |
| ១១ | កំពង់ធំ | ៧៣០ | ៩៨ | ៤៤ | ១៣ | ៨៨៥ | ១០ |
| ១២ | កំពង់ចាម | ៩០៩ | ១២០ | ៣៩ | ៤ | ១០៧២ | ១០ |
| | **សរុប** | **៦៧៩៦** | **១០១៥** | **៥៤៥** | **៦២** | **៨៤១៨** | **១២៣** |

ដើម្បីពង្រឹងគុណភាព និងបរិមាណចំណីអាហារដែលបានផ្តល់ដល់អ្នកទោស ក្រុមគ្រូពេទ្យបានផ្តល់គ្រាប់ពូជបន្លែ និងសំភារៈសំរាប់ដាំដុះទៅដល់ពន្ធនាគារចំនួន ១៦។ ការិយាល័យពេទ្យសង្ឃឹមថា នឹងបង្កើននូវបរិមាណចំណីអាហារបន្ថែមទៀតទៅដល់អ្នកទោស ហើយផ្តល់ឱកាសដើម្បីធ្វើការខាងក្រៅបន្ទប់ឃុំឃាំង។

កម្មវិធីសុខភាព និងអនាម័យបានប្រតិការនៅពន្ធនាគារទួលស្លែងតាំងពីខែធ្នូ ឆ្នាំ២០០៦មកម្លេះ ហើយជាលទ្ធផលជំងឺរមាស់ត្រូវបានលុបបំបាត់ (១០០%) និងជំងឺសើស្បែកត្រូវបានកាត់បន្ថយ (៨៤%)។ ការិយាល័យពេទ្យមានគំរោងដើម្បីពង្រីកកម្មវិធីទៅពន្ធនាគារដទៃទៀត។

## ករណីសិក្សា: ការធ្វើអន្តរាគមន៍ពេលសួរសុខទុក្ខក្នុងពន្ធនាគារ

នៅក្នុងឆ្នាំ២០០៧ កំឡុងធ្វើដំណើរទៅសួរសុខទុក្ខនៅពន្ធនាគារខេត្តកំពង់ចាម ក្រុមគ្រូពេទ្យបានទទួលពាក្យតូញត្អែរយ៉ាងច្រើនពីអ្នកទោសអំពីអំពើពុករលួយ និងភាពព្រងើយកន្តើយរបស់បុគ្គលិកពេទ្យពន្ធនាគារ ក្នុងការជ្រើសរើសអ្នកទោសមកព្យាបាល។ បន្ទាប់មក ក្រុមគ្រូពេទ្យបានស្នើសុំកិច្ចប្រជុំជាមួយប្រធានពន្ធនាគារដើម្បីពិភាក្សាពីកង្វល់របស់អ្នកទោស ហើយសំណូមពរឱ្យពួកគេអនុញ្ញាតិដើម្បីជ្រើសរើសអ្នកទោសទាំងនោះមកព្យាបាល។ ប្រធានពន្ធនាគារមិនបានសហការទេ ហើយគាត់និយាយថាគាត់មានការព្រួយបារម្ភយ៉ាងខ្លាំងពីសុវត្ថិភាពពន្ធនាគារ ហើយគាត់ខ្លាចពួកគេរត់ចេញ ដូច្នេះហើយបានជាគាត់មិនអនុញ្ញាតិឱ្យក្រុមគ្រូពេទ្យទាក់ទងជាមួយអ្នកទោសដែលមានជំងឺ។ បន្ទាប់ពីការចរចាយ៉ាងយូរមក ចុងបញ្ចប់ ប្រធានពន្ធនាគារក៏យល់ព្រមឱ្យក្រុមគ្រូពេទ្យចូលទៅព្យាបាលអ្នកទោស។

ក្នុងខែកក្កដា ឆ្នាំ២០០៧ ក្នុងខណៈពេលដែលចុះទៅពន្ធនាគារខេត្តព្រៃវែង ក្រុមគ្រូពេទ្យបានឮសំរែកអ្នកទោសម្នាក់ពីបន្ទប់ឃុំឃាំង។ ឆ្មាំពន្ធនាគារម្នាក់បានប្រាប់ថា អ្នកទោសម្នាក់នោះមានជំងឺក្រពះ។ ក្រុមគ្រូពេទ្យមានការព្រួយបារម្ភយ៉ាងខ្លាំងចំពោះអ្នកទោសនោះ នៅពេលដែលពួកគេបានព្យាបាលអ្នកទោសរួចហើយនៅថ្ងៃនោះ។ បន្ទាប់មក ពួកគេបានសំនូមពរចូលទៅពិនិត្យអ្នកទោសម្នាក់នោះក្នុងបន្ទប់ឃុំឃាំង ប៉ុន្តែសំណូមពរនោះត្រូវបានបដិសេធន៏ ហើយអ្នកទោសនោះត្រូវយកទៅកាន់បន្ទប់ព្យាបាលក្នុងពន្ធនាគារជំនួសវិញ។ អ្នកទោសម្នាក់អាយុ២៧ឆ្នាំ បានប្រាប់ក្រុមគ្រូពេទ្យយើងថា គាត់ត្រូវបានឆ្មាំពន្ធនាគារដាក់ច្រវាក់ជើងដោយសារតែគាត់បានឈ្លោះជាមួយបុរសដែលជាប់ពន្ធនាគារដូចគ្នា។ គាត់បានប្រាប់ក្រុមគ្រូពេទ្យថា គាត់មិនបានឈឺក្រពះទេ ប៉ុន្តែគាត់ដឹងថាប្រសិនបើគាត់ស្រែកនោះក្រុមគ្រូពេទ្យនឹងមកជួយគាត់។

ក្រុមគ្រូពេទ្យបានព្យាបាលដល់អ្នកទោសម្នាក់នោះ ហើយបន្ទាប់មកពួកគាត់ក៏បានជួបនឹងនាយករងពន្ធនារ ក្នុងគោលបំណងដើម្បីចរចា និងបញ្ចុះបញ្ចូលគាត់ឱ្យដោះច្រវាក់ជើងចេញពីអ្នកទោសនោះ។ ក្រោយពីការចរចាយ៉ាងយូរ នាយករងពន្ធនាគារបានយល់ព្រមដោះច្រវាក់ជើងពីអ្នកទោសនោះ។



### សេវាកម្មសំរាប់ជនរងគ្រោះដោយការបណ្តេញចេញ/តំបន់ទើបតាំងទីលំនៅថ្មី និងជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស

នៅក្នុងឆ្នាំ២០០៧ ការិយាល័យពេទ្យ បានព្យាបាលជនរងគ្រោះដោយការរំលោភសិទ្ធិមនុស្ស ចំនួន៥០២នាក់ (៣១៦នាក់ជាស្ត្រី) ជនរងគ្រោះករណីជំលោះដីធ្លី និងការ

បណ្តេញចេញចំនួន ៦,៩៥៦ (៥៣៣៧ នាក់ជាស្ត្រី) និងជន គ្រីក្រជាច្រើននាក់ទៀត ។

ការិយាល័យពេទ្យ ក៏បានផ្តល់ការព្យាបាលទៅដល់ជនរងគ្រោះរំលោភសិទ្ធិមនុស្សដែលបានបញ្ជូនមកពីការិយាល័យតាមបណ្តាខេត្តរបស់លីកាដូ ក៏ដូចជាពីអង្គការក្នុងស្រុក និងអន្តរជាតិជាផងដែរ ។ ក្នុងករណីអ្នកជំងឺមានសភាពធ្ងន់ធ្ងរ ការិយាល័យពេទ្យបានបញ្ជូនអ្នកជំងឺទៅកាន់មន្ទីរពេទ្យ និងមណ្ឌលដ៏ទៀតដែលអាចផ្តល់ការព្យាបាល ឬការស្តាលទ្ធភាពពលកម្មតាមតំរូវការ ។

**ករណីសិក្សា: ជនរងគ្រោះដោយជំលោះដីធ្លី**

សុវណ្ណា (ឈ្មោះប្រឌិត) មានអាយុ៣៣ឆ្នាំ ហើយសព្វថ្ងៃកំពុងរស់នៅក្នុងភូមិអណ្តូង (តំបន់តាំងទីលំនៅថ្មីសំរាប់សហគមន៍សំបុកចាបដែលត្រូវបានបណ្តេញចេញ) ក្រុងភ្នំពេញ។ នៅក្នុងខែមករា ឆ្នាំ២០០៧ គ្រួសារសុវណ្ណាបានទូរសព្ទមកក្រុមគ្រូពេទ្យលីកាដូដើម្បីសុំជំនួយ ។ សុវណ្ណាបានមានចុកពោះយ៉ាងខ្លាំង ហើយឈាមហូរចេញពីប្រដាប់ភេទ ។ ក្រុមគ្រូពេទ្យលីកាដូបានបញ្ជូននាងទៅមន្ទីរពេទ្យក្រុង ហើយបានចរចាជាមួយមន្ទីរពេទ្យជំនួសមុខឱ្យនាង ។ បន្ទប់ការពិនិត្យមកបានបង្ហាញថា នាងមានជំងឺមហារីកមាត់ស្បូន ។ បន្ទាប់មកក្រុមគ្រូពេទ្យលីកាដូបានយកនាងទៅកាន់ផ្នែកវះកាត់ខាងដុំពកនៃមន្ទីរពេទ្យសីហានុ ដែលជាកន្លែងនាងទទួលបានការព្យាបាលជាបន្តបន្ទាប់ ។ ក្នុងកំឡុងពេលនាងសំរាកព្យាបាលនៅមន្ទីរពេទ្យ ការិយាល័យពេទ្យលីកាដូបានផ្តល់ជាថវិការ ចំណីអាហារ ថ្នាំពេទ្យ និងសំភារៈជំនួយជាច្រើនជាផងដែរ ហើយតាមដានអាការៈរបស់នាងរហូតដល់នាងជាសះស្បើយ ។

***ការកសាងសមត្ថភាព***

ដើម្បីបង្កើនសមត្ថភាពបុគ្គលិក ការិយាល័យពេទ្យបានផ្តល់វគ្គបណ្តុះបណ្តាលផ្ទៃវេជ្ជសាស្ត្រប្រចាំខែចំនួន ១១ដង ។ លើសពីនេះទៅទៀត ការិយាល័យពេទ្យបានបញ្ជូនបុគ្គលិករបស់ខ្លួនទៅចូលរួមក្នុងវគ្គបណ្តុះបណ្តាលតាមបណ្តាអង្គការមិនមែនរដ្ឋាភិបាលដទៃទៀត ។

អង្គការលីកាដូយល់ថា ភាពជំនាញរបស់បុគ្គលិកអាចបង្កើនបានតាមការចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក ។ ដូចនេះហើយ បុគ្គលិកការិយាល័យពេទ្យបានចូលរួមប្រជុំ និងសិក្ខាសាលាជាច្រើនជាមួយបណ្តាអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ ដើម្បីបង្កើននូវជំនាញ និងបង្កើតបណ្តាញសុខភាព នៅក្នុងប្រទេសកម្ពុជាឱ្យកាន់តែរឹងមាំថែមទៀត ។

## ផលប៉ះពាល់

កាកិរិយាល័យពេទ្យបានផ្តល់ជំនួយផ្នែកសុខភាពទៅដល់មនុស្សជាង ៧,៤៥៨ នៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ២០០៧នេះ។ ប្រសិនបើគ្មានការិយាល័យពេទ្យទេ ជនរងគ្រោះនឹងមានការឈឺចាប់ដោយសារគ្មានការព្យាបាល និងការផ្តល់ដំបូន្មាន។ បន្ថែមលើការព្យាបាល ការងារការិយាល័យពេទ្យគឺធ្វើការជាមួយអ្នកទោស និងឆ្មាំពន្ធនាគារដើម្បីលើកកំពស់ការយល់ដឹងពីរបៀបដែលភាគីនីមួយៗគួរតែរំពឹងថាត្រូវបានការព្យាបាល និងធ្វើការដើម្បីជំនះវប្បធម៌អំពើហិង្សាដែលកើតមាននៅក្នុងប្រពន្ធ័ពន្ធនាគារ។

□□□

# ការិយាល័យទាក់ទាញមតិគាំទ្រ ធនធានឯកសារ និងព័ត៌មាន

ឯកសារដែលផ្តល់ដោយការិយាល័យលីកាដូដែលមានសមត្ថភាពខាងបច្ចេកទេសដើម្បីធ្វើអោយមានភាព ត្រឹមត្រូវ មិនលំអៀង សុក្រិតភាព និងភាពដែលអាចទុកចិត្តបានលើរបាយការណ៍ ហើយដើម្បីធានាបាននូវសុវត្ថិភាព និងការរក្សាទុកជាសំងាត់ចំពោះទិន្នន័យនៃការរំលោភសិទ្ធិមនុស្សដែលបានប្រមូលទុក។



**<u>គោលបំណង</u>**

- ផ្តល់អោយលីកាដូនូវឧបករណ៍ វិធីសាស្រ្ត និតិវិធី ទំរង់ កម្មវិធី និងអ្នកជំនាញការដើម្បីបង្កើននូវភាពត្រឹមត្រូវ មិនលំអៀង សុក្រិតភាព និងភាពដែលអាចជឿទុកចិត្តលើរបាយការណ៍ និងដើម្បីធានាអោយបាននូវសុវត្ថិភាព និងការរក្សាទុកជាសំងាត់ចំពោះទិន្នន័យនៃការរំលោភសិទ្ធិមនុស្ស។
- បង្កើនការសហប្រតិបត្តិការ និងពង្រឹងគុណភាពព័ត៌មានដែលបានចែកចាយព័ត៌មានទៅតាមបណ្តាការិយាល័យផ្សេងៗទៀតនៅក្នុងអង្គការលីកាដូ។
- បង្កើនជំនាញបច្ចេកទេសដល់បុគ្គលិក ទាំងការប្រមូលយកព័ត៌មាន ដំណើរការព័ត៌មាន ការវិភាគព័ត៌មាន និងការយល់ដឹងទៅលើបណ្តាញប្រព័ន្ធកំព្យូទ័រ។
- ដើម្បីអោយមានការយល់ដឹងកាន់តែច្បាស់អំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជាដោយប្រើប្រាស់នូវវិធីសាស្រ្តស្រាវជ្រាវសិក្សាសង្គម និងស្វែងរកការគាំទ្រមតិ។
- បង្កើតអោយលីកាដូនូវធនធានព័ត៌មានដែលអាចជឿជាក់បានសំរាប់ស្ថាប័នថ្នាក់ជាតិ ថ្នាក់តំបន់ និងការស្វែងរកមតិគាំទ្រទៅថ្នាក់អន្តរជាតិ។
- ពង្រឹងបណ្តាញព័ត៌មានជាមួយអង្គការជាតិ និងអន្តរជាតិនានា។

## លទ្ធផលសំរេចបាន

ការងារចំបងរបស់ ការិយាល័យធនធានឯកសារ និងព័ត៌មាន គឺធ្វើការចងក្រង និងបកប្រែករណីសំនុំរឿងពីការិយាល័យផ្សេងៗរបស់លីកាដូ (ការិយាល័យឃ្លាំមើលការរំលោភសិទ្ធិមនុស្ស ការិយាល័យសិទ្ធិកុមារ ការិយាល័យប្រឆាំងអំពើទារុណកម្ម និងការិយាល័យសិទ្ធិស្ត្រី) ទៅក្នុងប្រព័ន្ធទិន្នន័យកណ្តាលមួយ ដូច្នោះព័ត៌មានមានភាពងាយស្រួល និងមានសុវត្ថិភាពខ្ពស់ក្នុងការរក្សាទុក និងការវិភាគព័ត៌មាន។ លទ្ធផលការងាររបស់ការិយាល័យធនធានឯកសារ និងព័ត៌មានផ្សេងៗទៀតមានដូចជា: ការសំរបសំរួលលើការចែកចាយព័ត៌មានជាមួយការិយាល័យផ្សេងៗ ការរៀបចំវិភាគទិន្នន័យសំរាប់ប្រើប្រាស់ក្នុងការតស៊ូមតិ ការថែរក្សាធនធានឯកសារ ការបង្កើតឧបករណ៍ សំរាប់តស៊ូមតិ និងការកែប្រែគេហទំព័ររបស់អង្គការលីកាដូ។

កំឡុងឆ្នាំ ២០០៧ ការិយាល័យធនធានឯកសារ និងព័ត៌មានបានពង្រីកការចែកចាយព័ត៌មាន និងវិធីសាស្ត្រក្នុងការតស៊ូមតិដោយបោះពុម្ពព្រឹត្តិបត្រខាងក្នុងអង្គការចំនួន ១០ ច្បាប់ ព្រឹត្តិបត្រខាងក្រៅអង្គការចំនួន ៤ច្បាប់ (គំរោងផ្តល់ជំនួយម្ហូបអាហារដល់កុមារ និងនារីមានផ្ទៃពោះក្នុងពន្ធនាគារ -Adopt-A-PrisonProject) ការស្រាវជ្រាវ និងព្រាងអត្ថបទព័ត៌មានចំនួន ១២ រឿងដែលទទួលបានជោគជ័យ ហើយក៏បានផលិតព័ត៌មានសោតទស្សន៍ភាសាខ្មែរចំនួន ៨ សំរាប់ដាក់លើគេហទំព័រ អង្គការលីកាដូ។

### *របាយការណ៍*

ការិយាល័យធនធានឯកសារ និងព័ត៌មាន ក៏បានផលិតរបាយការណ៍សោតទស្សន៍ជាភាសាខ្មែរសំរាប់អង្គការលីកាដូ ចំនួន ៣ គឺ:

- ស្ថានភាពពន្ធនាគារនៅប្រទេសកម្ពុជា ឆ្នាំ ២០០៥ និង ២០០៦: មួយថ្ងៃក្នុងជីវភាពរស់នៅជា . . .
- អំពើហិង្សាប្រឆាំងនារីភេទ: តើច្បាប់កម្ពុជារើសអើងប្រឆាំងនារីភេទដោយរបៀបណា
- សិទ្ធិមនុស្សនៅកម្ពុជា: យុត្តិធម៌គ្មានភាពប្រាកដនិយម







របាយការណ៍សោតទស្សន៍អាចជួយក្នុងការផ្សព្វផ្សាយរបាយការណ៍ទាំងនេះអោយកាន់តែទូលំទូលាយទៅសហគមន៍នៅក្នុងប្រទេសកម្ពុជាដែលភាគច្រើនមិនចេះអក្សរហើយរស់នៅតាមបណ្តាខេត្តនានា ឬរស់នៅក្រៅប្រទេស ហើយពួកគេអាចដោនឡូដយករបាយការណ៍ទាំងនោះបាន។ នៅក្នុងឆ្នាំ២០០៧ របាយការណ៍លីកាដូ ចំនួន ៩៨៤៨ ស៊ីឌីចំនួន ៣១៩៥ និងកាសែតចំនួន ១០០០ ដុំ ត្រូវបានផលិត និងបោះពុម្ពផ្សាយ។

## គេហទំព័ររបស់អង្គការលីកាដូ




នៅក្នុងឆ្នាំ២០០៧ នេះគេហទំព័ររបស់លីកាដូនៅតែបន្តហើយមានការកែប្រែអោយកាន់តែប្រសើរឡើងជាងមុន។ ឆ្នាំនេះ គេហទំព័របានបង្ហាញអោយឃើញការបន្ថែមនូវលីកាដូវិទ្យុនៅលើគេហទំព័រដែលបានបង្ហាញ ព័ត៌មានសោតទស្សន៍ប្រចាំខែជាភាសារខ្មែរ និងរបាយការណ៍សោតទស្សន៍។ ព្រឹត្តិប័តប្រចាំខែ និងមាតិកាជាភាសាខ្មែរ និងភាសាអង់គ្លេស ត្រូវបានដាក់បន្ថែមនៅលើគេហទំព័រដើម្បីអោយមានភាពងាយស្រួល។

ស្ថិតិខ្លះសំរាប់គេហទំព័រអង្គការលីកាដូមានដូចជា :

- អ្នកបើកគេហទំព័រចំនួន ៥៧ ៤៧១ នាក់ បានបើកមើល ៣៤៩ ៦៦៧ ទំព័រ នៅលើគេហទំព័របើគិតជាមធ្យមទៅលើអ្នកចូលទស្សនាក្នុងមួយខែ។




- **ប្រទេសប្រាំ ដែលនិយមចូលទស្សនាគេហទំព័រមាន:**
  - ១. សហរដ្ឋអាមេរិច (២១៨៧៨០ ទំព័រ)
  - ២. អូស្ត្រាលី (៥០០៥៥ទំព័រ)
  - ៣. កម្ពុជា (១៣១៨៧ ទំព័រ)
  - ៤. កាណាដា (១១៦៤៦ ទំព័រ)
  - ៥. សហគមន៍អឺរ៉ុប (៧ ៩៩៧ ទំព័រ)

  (ចំណាំ: ប្រទេសពីរខាងលើបានទទួលជនភៀសខ្លួនកម្ពុជាជាច្រើនទៅរស់នៅ)

- **ទំព័រ និងប្រធានបទសំខាន់ៗ បី ដែលបង្ហាញនៅលើគេហទំព័រ:**
  - ១. កំរងរូបភាព
  - ២. របាយការណ៍
  - ៣. លីកាដូវិទ្យុ




- **ពាក្យស្វែងរកសំខាន់ៗ ចំនួន បីដែលប្រើសំរាប់ចូលក្នុងគេហទំព័រ:**
  - ១. អង្គការក្រៅរដ្ឋាភិបាលនៅកម្ពុជា
  - ២. អំពើទារុណកម្ម
  - ៣. ពលកម្មកុមារនៅកម្ពុជា

## *ប្រព័ន្ធទិន្នន័យ ( Database )*

តារាងខាងក្រោមនេះបង្ហាញពីចំនួនករណី (៩២២) ដែលការិយាល័យធនធានឯកសារ និងព័ត៌មានបានបកប្រែ ជាភាសាអង់គ្លេសហើយបានបញ្ចូលទៅក្នុង Database នៅក្នុងឆ្នាំ ២០០៧។ ករណីខ្លះបាន ស្រង់យកមកពីឆ្នាំ២០០៦។ ការិយាល័យធនធានឯកសារ និងព័ត៌មានបានធ្វើការទៅលើការងារដែលដាក់អោយដូច ជាការស្រាវជ្រាវ ការធ្វើពង្រាង ផលិត និងកែតំរូវឧបករណ៍តស៊ូមតិ និងសម្ភារៈមួយចំនួន ហេតុដូចនេះហើយមានកិច្ចការនៅសល់យចំនួនធំបានកើនឡើង ហើយការិយាល័យធនធានឯកសារ និងព័ត៌មានត្រូវតែចាំបាច់ដោះស្រាយបញ្ហាទាំងនោះ។

**ចំនួនករណីដែលបានបកប្រែ និងបានបញ្ចូលទៅក្នុងប្រព័ន្ធទិន្នន័យដោយ ADRO ក្នុងឆ្នាំ២០០៧**




## លទ្ធផលសំរេចបាន

- ស្ថិតិនៃការរំលោភបំពានសិទ្ធិមនុស្ស ត្រូវបានធ្វើឡើងអោយមានភាពងាយស្រួល និងកត់ត្រាទុកយ៉ាងត្រឹមត្រូវ។ ដែលនេះធ្វើអោយមានការកើនឡើងនូវប្រសិទ្ធិភាពក្នុងការរក្សាទុកករណីសំនុំរឿង។
- អត្ថបទព័ត៌មាន និងរឿងដែលទទួលជោគជ័យ (រួចចសេសព្រត្យរិសេ) ត្រូវចេញផ្សាយនៅលើគេហទំព័រ
- របស់អង្គកាលីកាដូ ដែលបានផ្តល់សំភារៈតស៊ូមតិទៅអោយសាធារណៈជនលើប្រធានបទបញ្ហាសិទ្ធិមនុស្ស។
- ព្រឹត្តិប័តខាងក្នុងអង្គការជួយអោយបុគ្គលិកនៃអង្គការលីកាដូ បានចែករំលែកពីបញ្ហាសង្គមនិងបញ្ហារបស់បុគ្គលិក។

- លទ្ធិភាពរបស់ការិយាល័យធនធានឯកសារ និងព័ត៌មាន ក្នុងការជួយដល់គ្រប់ទំរង់ទាំងអស់នៃការផលិតរបាយការណ៍ជាសាធារណៈរបស់អង្គការលីកាដូ (ការស្រាវជ្រាវ ការចងក្រងឯកសារ ការបកប្រែ ការកែតំរូវ និងការថតជាសោតទស្សន៍) បានបង្កើនសមត្ថភាពអោយអង្គការលីកាដូក្នុងការផលិតរបាយការណ៍អោយទាន់ពេល។

□□□

# ការិយាល័យអប់រំសិទ្ធិមនុស្ស

គ្រូអប់រំផ្នែកសិទ្ធិមនុស្សលីកាដូបើកវគ្គហ្វឹកហ្វឺនរយៈពេលបីថ្ងៃជាប្រចាំស្តីពីសិទ្ធិមនុស្ស នីតិវិធីច្បាប់ គោលការណ៍ប្រជាធិបតេយ្យដល់ក្រុមគោលដៅដែលបានជ្រើសរើសមួយចំនួនដូចជាមន្ត្រីនគរបាល សិស្ស-និស្សិត និងព្រះសង្ឃដោយប្រើប្រាស់នូវព័ត៌មានអប់រំយ៉ាងច្រើន តាមបែបវិធីសាស្ត្រហ្វឹកហ្វឺននៃការចូលរួមមតិយោបល់ពីក្រុម ។ គ្រូអប់រំនៃអង្គការលីកាដូនៅតាមបណ្តាខេត្ត-ក្រុង បានផ្សព្វផ្សាយនូវព័ត៌មានស្តីពីសិទ្ធិមនុស្សដល់ សាធារណៈជនទូទៅតាមមូលដ្ឋានភូមិ-ឃុំ និងស្រុកនានាផងដែរ ។



## គោលបំណង

- ដើម្បីផ្តល់ចំណេះដឹងប្រកបដោយប្រសិទ្ធិភាពដល់ប្រជាពលរដ្ឋកម្ពុជាគ្រប់លំដាប់ថ្នាក់ ស្ថានភាពអប់រំ និងកាលៈទេសៈស្តីពីសិទ្ធិមនុស្សជាសាកលដែលពួកគេទទួលបានពីអ្នកដទៃ និងមានជាកម្មសិទ្ធិ ។
- ដើម្បីចែករំលែកនូវចំនេះដឹងស្តីអំពីសិទ្ធិមនុស្សទៅដល់បុគ្គលម្នាក់ៗ ក្រុមគ្រួសារ និងសហគមន៍ដូចជា ពួកគេអាចម្ចាស់ការលើសកម្មភាពផ្ទាល់ខ្លួន និងជះឥទ្ធិពលជាវិជ្ជមានទៅលើការដោះស្រាយជំលោះដោយសន្តិវិធី និងការបំពាក់បំប៉នបញ្ចូលគ្នា និងការចូលរួម ។
- ដើម្បីធ្វើការចងភ្ជាប់ និងធ្វើការសាកល្បងទៅលើបណ្តុំដែលជាប់ពាក់ព័ន្ធ ការអនុវត្តន៍ និងវិធីសាស្ត្រសិក្សាដ៏មានប្រសិទ្ធិភាពដើម្បីប្រើប្រាស់យុទ្ធវិធីសំរាប់សិក្សាដោយយល់ដឹងផ្ទាល់ពីតំរូវការច្បាស់លាស់របស់ក្រុមគោលដៅ ហើយត្រូវបានគេកំណត់ទុក ដើម្បីបន្តរំលឹកឡើងវិញនូវការអនុវត្តន៍សិទ្ធិមនុស្សនៅកម្ពុជា ។
- ដើម្បីកំណត់អោយឃើញពីសមាជិកនៅក្នុងសង្គមហើយដែលក្នុងនោះវាជាតំរូវការចាំបាច់ក្នុងការយល់ដឹងពីសិទ្ធិមនុស្សព្រមទាំងសិទ្ធិផ្សេងៗទៀតដែលត្រូវគេរំលោភបំពាន ឬជួបឧបសគ្គ និងអ្នកដែលមានតួនាទីជួយអ្នកទាំងនោះតាមតំរូវការ ។
- រៀបចំវគ្គបណ្តុះបណ្តាលស្តីពីសិទ្ធិមនុស្សនិងកម្មវិធីផ្សព្វផ្សាយស្តីពីសិទ្ធិមនុស្សដើម្បីធ្វើការជ្រើសរើសយកក្រុមគោលដៅ ។
- ដើម្បីអភិវឌ្ឍន៍ និងបង្កើតអោយមានបទពិសោធន៍នៃការអប់រំ និងសំភារៈជាមធ្យោបាយសមរម្យបំផុតសំរាប់ជាសញ្ញាណដើម្បីយល់ដឹង និងអនុវត្តន៍តទៅមុខទៀត ។

- ដើម្បីបន្តការបង្កើតចំណងទំនាក់ទំនងជាមួយសិក្ខាកាម និងសហគមន៍ដើម្បីជួយសំរបសំរួលក្នុងការត្រួតពិនិត្យដំណើរការវគ្គហ្វឹកហ្វឺននៅពេលខាងមុខសំរាប់ជាជំនួយបន្ថែម និងបន្តតាមដានសកម្មភាព។
- ដើម្បីសំរេចបាននូវការរក្សាលទ្ធផលការរីកចំរើននៃក៏រិតជំនាញនិងចំណេះដឹងដែលបានយល់ជ្រាបរបស់សិក្ខាកាមទាក់ទងនឹងជំនាញ និងធ្វើការរំលឹកឡើងវិញបន្ទាប់ពីរយៈពេល៦ខែ និងបង្ហាញនូវអ្វីដែលពួកគេបានសិក្សា។
- ដើម្បីផ្តល់ការណែនាំជាគំនិតអោយដល់សហគមន៍ អំពីការឃ្លាំមើល និងសេចក្តីព្រួយបារម្ភទៅលើបញ្ហាសិទ្ធិមនុស្សសំរាប់អង្គការលីកាដូ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀតដើម្បីអោយមានអាជ្ញាធរចូលរួមច្រើន។
- ដើម្បីកំណត់សំគាល់បង្ហាត់បង្ហាញនិងលើកទឹកចិត្តដល់ប្រជាពលរដ្ឋដែលមានលទ្ធភាពអោយបន្តចូលរួមលើកកំពស់សិទ្ធិមនុស្សនៅក្នុងសហគមន៍របស់ពួកគេ។

## លទ្ធផលសំរេចបាន

ក្នុងឆ្នាំ២០០៧ សម្មភាពចំបងរបស់ការិយាល័យអប់រំសិទ្ធិមនុស្ស គឺរៀបចំ និងបើកវគ្គហ្វឹកហ្វឺនស្តីអំពីសិទ្ធិមនុស្សដែលរួមទាំងការធ្វើការផ្សព្វផ្សាយ និងការអភិវឌ្ឍន៍មេរៀនសំរាប់វគ្គបណ្តុះបណ្តាសិទ្ធិមនុស្ស។

សកម្មភាពទាំងនោះត្រូវបានរៀបចំឡើងដើម្បីបំរើសេចក្តីត្រូវការរបស់ក្រុមគោលដៅចំនួន ៧ រួមមាន : សិស្សនៅមធ្យមសិក្សា និស្សិតមហាវិទ្យាល័យ ព្រះសង្ឃ ប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំសង្កាត់ បណ្តាញសហគមន៍ជនរងគ្រោះដោយការរំលោភដីធ្លី មន្ត្រីប៉ូលី និងប្រជាពលរដ្ឋទូទៅ។

## *សកម្មភាពចំបង១នៃការហ្វឹកហ្វឺន*

វគ្គហ្វឹកហ្វឺនស្តីអំពីសិទ្ធិមនុស្សត្រូវបានផ្តល់ដោយការិយាល័យអប់រំសិទ្ធិមនុស្សរួមមាន វគ្គសិក្សាចំនួន៣ថ្ងៃ វគ្គតាមដានចំនួន១ថ្ងៃ និងវេទិការសេរីចំនួនកន្លះថ្ងៃ។ នៅក្នុងកំឡុងវគ្គសិក្សាទាំងនេះ សំភារៈតស៊ូមតិត្រូវបានចែកជូន ហើយតារាងខាងក្រោមនេះបង្ហាញពីចំនួនវគ្គហ្វឹកហ្វឺនដែលបានរៀបចំ និងបង្ហាញថាស្ត្រីបានចូលរួមច្រើនជាងពាក់កណ្តាលនៃសិក្ខាកាមសរុប។

| វគ្គហ្វឹកហ្វឺនដែលបានរៀបចំនៅក្នុងឆ្នាំ ២០០៧ | | | |
|---|---|---|---|
| **ប្រភេទវគ្គហ្វឹកហ្វឺន** | **វគ្គដែលបានរៀបចំ** | **សិក្ខាកាមដែលបានហ្វឹកហ្វឺន** | **សិក្ខាកាមស្ត្រី** |
| វគ្គរយៈពេល៣ ថ្ងៃ | ៤៤ | ១៤៤៣ | ៧៥២ |
| វគ្គបណ្តាញ ១ ថ្ងៃ | 0 | 0 | 0 |
| វគ្គតាមដាន ១ ថ្ងៃ | 0 | 0 | 0 |
| វគ្គផ្សព្វផ្សាយ ១ថ្ងៃ | ១២៤ | ៥០៣៥ | ៣១៥១ |
| **សរុប** | **១៦៨** | **៦៤៧៨** | **៣៩០៣** |

ការប្តេជ្ញារបស់ការិយាល័យអប់រំសិទ្ធិមនុស្ស ដើម្បីធ្វើការលើកកំពស់សាមគ្គីភាពយ៉ាងទូលាយជាមួយអង្គការក្រៅរដ្ឋាភិបាលសំខាន់ដ៏ទៃផ្សេងទៀតដែលមានវគ្គសហការគ្នាចំនួន ៣០ ត្រូវបានរៀបចំឡើងនៅក្នុងឆ្នាំ ២០០៧។ បន្ថែមលើនេះទៀត គ្រូអប់រំសិទ្ធិមនុស្សប្រចាំការិយាល័យភ្នំពេញបានសហការជាមួយគំរោងសិទ្ធិកុមារនៅសង្កាត់ដង្កោចំនួន ២៩ដង ដែលនៅទីនោះក្រុមការពារកុមារបាននឹងកំពុងរៀបចំប្រជុំ និងធ្វើការផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ។

## *ការបង្កើតកម្មវិធីសំរាប់វគ្គហ្វឹកហ្វឺន*

សកម្មភាពចំបងផ្សេងៗទៀតរបស់ការិយាល័យអប់រំសិទ្ធិមនុស្សគឺ ដើម្បីធ្វើការអភិវឌ្ឍន៍ ការប្រមូលផ្តុំ ការបង្កើតការ ផ្លាស់ប្តូរ និងការកែប្រែសំភារៈ សំរាប់ការហ្វឹកហ្វឺនសិទ្ធិមនុស្សដើម្បីគ្រាំទ្រសម្មភាពហ្វឹកហ្វឺនសិទ្ធិមនុស្សនៅក្នុងភ្នំពេញ និងក្នុង ១២ខេត្ត។ សំភារៈសិក្សារួមមាន សៀវភៅណែនាំ សៀវភៅរូបភាពសំរាប់អ្នកចេះ និងមិនចេះអក្សរ ខិត្តប័ណ្ណ កូនសៀវភៅច្បាប់ ផ្ទាំងរូបភាព អាវយឺត វិញ្ញាបនប័ត្រចូលរួមរបស់សិក្ខាកាមប្រតិទិន និងឯកសារចែកជូនផ្សេងៗទៀត។ គ្រប់សំភារៈសិក្សាទាំងអស់ត្រូវបានធ្វើឡើងជាភាសាខ្មែរ។ ឯកសារចែកជូននៅក្នុងវគ្គបណ្តុះបណ្តាលត្រូវបានព្រាងឡើងនៅក្នុងឆ្នាំ២០០៧ រួមមានៈ

- ការតស៊ូមតិ និងសហគមន៍
- លទ្ធិប្រជាធិបតេយ្យពិតប្រាកដ
- សេចក្តីណែនាំសំរាប់វេទិការពិភាក្សាអំពីសិទ្ធិមនុស្ស និងកម្មវិធីជជែកពិភាក្សា

បន្ថែមទៅលើនេះទៀត” ច្បាប់រៀបអាពាហ៍ពិពាហ៍ និងគ្រួសារ” និង” ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ” ត្រូវបានរៀបចំ និងបោះពុម្ពឡើងវិញ។

## *ការកសាងសមត្ថភាពរបស់បុគ្គលិក*

ដោយសារកង្វះខាតថវិការ ទើបបុគ្គលិកនៃការិយាល័យអប់រំសិទ្ធិមនុស្សទាំងអស់មិនមានលទ្ធភាពចូលរួមនៅក្នុងវគ្គហ្វឹកហ្វឺនខាងក្រៅ។ ទោះបីជាយ៉ាងណាក៏ដោយ មានបុគ្គលិកមួយចំនួនបានចូលរួមក្នុងវគ្គអភិវឌ្ឍន៍បុគ្គលិកដែលរៀបចំឡើង ដោយអង្គការលីកាដូ រឺអង្គការក្រៅរដ្ឋាភិបាលជាដៃគូផ្សេងទៀត។ វគ្គទាំងនោះរួមមាន ជំនាញទំនាក់ទំនង ជំនាញកុំព្យូទ័រ វគ្គស្តីអំពីក្រមនីតិវិធីព្រហ្មទណ្ឌថ្មី វគ្គតស៊ូមតិសំរាប់សហគមន៍ និងវគ្គតស៊ូមតិនៅជនបទដាច់ស្រយាល។

## <u>**លទ្ធផលសំរេចបាន**</u>

សកម្មភាពចូលរួមរបស់ការិយាល័យអប់រំសិទ្ធិមនុស្ស បានផ្តល់ឱកាសអោយអតិថិជនក្នុងការស្វែងរកការណែនាំទាំងឡាយទាក់ទងទៅនឹងបញ្ហាផ្ទាល់របស់ពួកគេ។ ចំនួនករណីពិតប្រាកដត្រូវកើនឡើងដោយមានការចូលរួមរបស់សិក្ខាកាមដែលរងគ្រោះដោយការរំលោភសិទ្ធិមនុស្សហើយក្នុងនោះដំណោះស្រាយដ៏មានប្រសិទ្ធិភាពត្រូវបានផ្តល់ជូនដើម្បីជួយទប់ស្កាត់ការរំលោភបំពានកុំអោយបន្តទៅពេលខាងមុខទៀត។

អង្គការជាតិ និងអន្តរជាតិនៅតែមានចំណាប់អារម្មណ៏ទៅលើការអប់រំសិទ្ធិមនុស្ស និងបានស្នើរសុំអោយមានវគ្គហ្វឹកហ្វឺនអាយច្រើនជាងមុនសំរាប់ក្រុមគោលដៅ និងបុគ្គលិករបស់ពួកគេ។ ជាមួយគ្នានេះផងដែល បុគ្គលសហគមន៍ និងអាជ្ញាធរមូលដ្ឋានក៏បានស្នើរសុំអោយមានវគ្គហ្វឹកហ្វឺន និងវគ្គផ្សព្វផ្សាយសំរាប់ប្រពលរដ្ឋរស់នៅតំបន់ដាច់ស្រយាលដែរ។

□□□